វិទ្យាស្ថាន ជាតិអប់រំ

National Institute of Education

កិច្ចការស្រាវជ្រាវ

ម៉ាទ្រីស

រៀបរៀងដោយៈ គរុនិស្សិតគណិតវិទ្យាក្រុម១

ជំនាន់ទី២៤

គ្រូណែនាំៈ ហួត សុខលឿន

ឆ្នាំសិក្សា ២០១៨~២០១៩

២០១៩ ⓢ សៀវភៅសម្រាប់អ្នកសិក្សាទូទៅ ⓢ

ក្រសួងអប់រំ យុវជន និងកីឡា

វិទ្យាស្ថានជាតិអប់រំ

សៀវភៅ ម៉ាទ្រីស

កិច្ចការស្រាវជ្រាវរបស់គរុនិស្សិតបរិញ្ញា+១

មុខវិជ្ជា៖ គណិតវិទ្យា

គរុនិស្សិតជំនាន់ទី ២៤

គ្រូណែនាំ៖ ហួត សុខលឿន

គរុនិស្សិត

១. ហ៊ីង វុទ្ធី

២. ហាម វណ្ណឌី

៣. នីម តារម្យ

៤. អៀត សារី

៥. ស្នួង សុតា

អារម្ភកថា

សួស្តីអ្នកសិក្សាទាំងឡាយជាទីគោរពរាប់អាន!

សៀវភៅ **ម៉ាទ្រីស** ដែលលោកអ្នកកំពុងតែកាន់នៅក្នុងដៃនេះ ត្រូវបានរៀបចំឡើងដោយក្រុម គរុនិស្សិត ឯកទេស គណិតវិទ្យា ក្រុម១ ជំនាន់ទី២៤ ក្រោមការណែនាំពីលោកគ្រូ **ហួត សុខឿន** ដែលជាសាស្ត្រាចារ្យនៃវិទ្យាស្ថានជាតិអប់រំ ។ សៀវភៅនេះរៀបចំឡើងក្នុងគោលបំណងចង់ឲ្យអ្នកសិក្សាទាំងឡាយមានភាពងាយស្រួលក្នុងកាសិក្សាស្រាវជ្រាវទៅលើមេរៀនម៉ាទ្រីស និង ដើម្បីទុកជាឯកសារជំនួយមួយដល់ប្អូនៗសិស្សានុសិស្ស ថ្នាក់ទី១១-១២ និង ប្អូនៗនិស្សិតថ្នាក់មហាវិទ្យាល័យដែលកំពុងតែត្រូវការសៀវភៅ **ម៉ាទ្រីស** នេះក្នុងការហ្វឹកហាត់ ដោះស្រាយលំហាត់ម៉ាទ្រីសផ្សេងៗ ។ នៅក្នុងសៀវភៅនេះ យើងខ្ញុំបានបែងចែកជា បីផ្នែកធំៗ គឺ ទី១ផ្នែក មេរៀន ទី២ផ្នែកលំហាត់មានដំណោះស្រាយ និងទី៣ផ្នែកលំហាត់អនុវត្តន៍ ។ នៅក្នុងផ្នែក មេរៀនយើងខ្ញុំបានបញ្ចូលទាំង និយមន័យ ទ្រឹស្តី បំណកស្រាយ ឧទាហរណ៍ និងចំណុចសម្គាល់ផ្សេងៗ ងាយយល់ និងងាយចងចាំ ។ ចំណែកឯ ផ្នែកលំហាត់មានដំណោះស្រាយ យើងខ្ញុំបានខិតខំសម្រិតសម្រាំងលំហាត់ល្បីៗល្អៗ ដែលដកស្រង់ចេញពីវិញ្ញាសាប្រឡងប្រជែងនានាទាំងក្នុងស្រុក និងក្រៅស្រុក និងចេញពីសៀវភៅខ្មែរ និងបរទេសល្បីៗថែមទៀតផង ហើយសម្រាប់ផ្នែកលំហាត់អនុវត្តន៍ យើងខ្ញុំបន្ថែមនូវចម្លើយពីក្រោយផងដែរ ។ តែទោះបីជាយើងខ្ញុំ ខិតខំយកចិត្តទុកដាក់អស់ពីសមត្ថភាពយ៉ាងណា ក៏ការរៀបរៀងនេះមិនប្រាកដថា មិនមានចំណុច ខ្វះខាត ឬ កំហុសឆ្គងណាមួយដោយអចេតនានោះទេ ទាំងផ្នែកបច្ចេកទេស និងអក្ខរាវិរុទ្ធ ។ អាស្រ័យហេតុនេះ យើងខ្ញុំ ដែលជា ក្រុមអ្នករៀបរៀងរង់ចាំដោយរីករាយនូវការរិះគន់ក្នុងន័យស្ថាបនាពី សំណាក់អ្នកសិក្សាទូទៅគ្រប់មជ្ឈដ្ឋាន ដើម្បីជួយកែលម្អសៀវភៅមួយនេះឲ្យកាន់តែត្រឹមត្រូវ ទូលំទូលាយ និងប្រសើរឡើងថែមមួយកម្រិតទៀត។ ជាចុងក្រោយ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សៀវភៅម៉ាទ្រីសមួយនេះនឹងក្លាយជាទុនមួយយ៉ាងសំខាន់សម្រាប់សិស្សានុសិស្ស និស្សិត លោកគ្រូ អ្នកគ្រូ និងអ្នកសិក្សាទូទៅយកទៅប្រើប្រាស់ទុកជាឯកសារស្រាវជ្រាវមួយ ។ យើងខ្ញុំ សូមគោរពជូនពរ លោកគ្រូ អ្នកគ្រូ លោក/លោកស្រី និងមិត្តអ្នកសិក្សាទាំងអស់ឲ្យមានសុខភាពល្អ រឹងមាំ មានភាពជោគជ័យក្នុងការសិក្សា និងគ្រប់ភារកិច្ច ។

ថ្ងៃចន្ទ ១៤ រោច ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី០១ខែកក្កដា ឆ្នាំ២០១៩

គរុនិស្សិតគណិតវិទ្យា ក្រុម១ ជំនាន់ទី២៤

សេចក្តីថ្លែងអំណរគុណ

ជាបឋម យើងខ្ញុំដែលជាអ្នករៀបរៀងសៀវភៅនេះ សូមនឹករលឹកគុណជូនចំពោះមាតាមិតា លោកគ្រូអ្នកគ្រូព្រមទាំងអ្នកមានគុណទាំងឡាយដែលបានជំរុញ ពួកយើងខ្ញុំហូតក្លាយទៅជាគរុនិស្សិតហើយនឹងក្លាយជាគ្រូបង្រៀន ក្នុងពេលខាងមុខនេះ សម្រាប់អប់រំក្មេងៗជំនាន់ក្រោយឱ្យក្លាយជាសរសរទ្រូងនៃប្រទេសជាតិ។ ប្រសិនបើគ្មានវត្តមានអស់លោកអ្នកទាំងអស់ទេ ពួកយើងខ្ញុំក៏មិនមានថ្ងៃនេះដែរ។

សូមគោរពអរព្រះគុណជូនចំពោះលោកឪពុក អ្នកម្តាយជាព្រះកន្លោងដែលបានផ្តល់ជីវិត ក៏ដូចជាក្តីស្រលាញ់ និងសម្ភារៈសម្រាប់ទ្រទ្រង់ដល់ការសិក្សារៀនសូត្ររបស់កូនៗ តាំងពីតូចរហូតដល់ពេលបច្ចុប្បន្ន។

សូមគោរពអរគុណជូនចំពោះលោកគ្រូ អ្នកគ្រូគ្រប់កម្រិតតាំងពីមត្តេយ្យសិក្សា រហូតដល់ឧត្តមសិក្សាជាពិសេសលោកគ្រូអ្នកគ្រូ ដែលជាគ្រូឧទ្ទេស និងគណៈគ្រប់គ្រងវិទ្យាស្ថានជាតិអប់រំ ដែលបានបង្ហាត់បង្រៀនយើងខ្ញុំឱ្យក្លាយជាធនធានមនុស្សសម្រាប់ការអភិវឌ្ឍប្រទេសជាតិ។

សូមថ្លែងអំណរគុណចំពោះអ្នកមានគុណទាំងឡាយមាន បងប្អូន ជីដូនជីតា មិត្តភក្តិ និងអ្នកទាំងឡាយដែលបានជួយជ្រោមជ្រែង និងបានផ្តល់នូវបទពិសោធន៍ល្អៗ ក៏ដូចជាសកម្មភាពនានាពាក់ព័ន្ធនឹងដំណើរការសិក្សានេះផងដែរ។

ជាចុងបញ្ចប់ យើងខ្ញុំសូមជូនពរអ្នកមានគុណទាំងអស់ សូមប្រកបដោយសុខភាពល្អបរិបូរណ៍ សុភមង្គល់ សុខសុវត្ថភាព និងទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរព្រះគុណ និងអរគុណ!

ថ្ងៃចន្ទ ១៤ រោច ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី០១ខែកក្កដា ឆ្នាំ២០១៩

គរុនិស្សិតគណិតវិទ្យា ក្រុម១ ជំនាន់ទី២៤

មូលន័យសង្ខេប

ដោយយោងតាមតម្រូវការរបស់សិស្សានុសិស្សដែលកំពុងសិក្សាថ្នាក់នៅកម្រិតវិទ្យាល័យ និងសិស្សនិស្សិតនៅតាមបណ្ដាមហាវិទ្យាល័យនានា ទើបក្រុមយើងខ្ញុំ បានសិក្សាស្រាវជ្រាវលើប្រធានបទ **ម៉ាទ្រីស** ដើម្បីទុកជាឯកសារស្រាវជ្រាវបញ្ចប់ឆ្នាំសិ ក្សានៅវិទ្យាស្ថានជាតិអប់រំគណិតក្រុម១ ជំនាន់ទី២៤ និងទុកជាឯកសារសម្រាប់សិស្សនិស្សិតដែលត្រូវការចាំបាច់ផងដែរ។

សៀវភៅនេះបានបែងចែកជាជំពូកធំៗគឺ ជំពូកទី១និយាយអំពី **ម៉ាទ្រីស** បានសរសេររៀបរាប់អំពីផ្នែកនេះមេរៀននីមួយរួចមាននិយមន័យ ទ្រឹស្ដីបទ និងឧទាហរណ៍ ។ ជំពូកទី២ គឺនិយាយអំពី **ការអនុវត្តន៍ម៉ាទ្រីសនៅលើមេរៀនវ៉ិចទ័រនិងបរមាភម្ម** និងមានលំហាត់ឧទាហរណ៍ផងដែរ ។ បន្ទាប់ពីមេរៀនមកចូលដល់ផ្នែកលំហាត់ មានដំណោះស្រាយ ។ ជាចុងបញ្ចប់នៃសៀវភៅនេះមានលំហាត់អនុវត្តន៍ ដែលមានចម្លើយដើម្បីផ្ទៀងផ្ទាត់ ។

មាតិកា

ជំពូក១ ម៉ាទ្រីស

១. សញ្ញាណនៃម៉ាទ្រីស

នៅក្នុងហាងធំមួយ គេមានអាវយឺតមានបីទំហំនិងពណ៌ចំនួនប្រាំផ្សេងៗគ្នា ។ ដោយអាវយឺតពណ៌ក្រហម មានទំហំមធ្យមចំនួន 3 និងទំហំធំមានចំនួន 1, អាវយឺតពណ៌ស មានទំហំតូចមានចំនួន 9 និងទំហំមធ្យមចំនួន 5 , អាវយឺតពណ៌ខៀវ មានទំហំតូចមានចំនួន 8 និងទំហំមធ្យមចំនួន 6, អាវយឺតពណ៌បៃតង មានទំហំមធ្យមចំនួន 5 និងទំហំធំមានចំនួន 3, អាវយឺតពណ៌ខ្មៅ មានទំហំតូចមានចំនួន 7 ទំហំមធ្យមចំនួន 1 និងទំហំធំមានចំនួន 2 ។ ដោយសារតែពណ៌មានដែលទាក់ទង់នឹងអាវយឺតមានភាពស្មុកស្មាញ ទើបអ្នកគ្រប់គ្រងហាងបានរៀបចំនួនទិន្នន័យរបស់អាវយឺតជាជួរឈរ និងជួដេកដូចខាងក្រោមដើម្បីងាយស្រួលយល់ ។

$$\begin{array}{c} \\ \text{តូច} \\ \text{មធ្យម} \\ \text{ធំ} \end{array} \begin{array}{c} \begin{array}{ccccc} \text{ក្រហម} & \text{ស} & \text{ខៀវ} & \text{បៃតង} & \text{ខ្មៅ} \end{array} \\ \begin{pmatrix} 0 & 9 & 8 & 0 & 7 \\ 3 & 5 & 6 & 5 & 1 \\ 1 & 0 & 0 & 3 & 2 \end{pmatrix} \end{array} \qquad (១.១)$$

ការតម្រៀបទិន្នន័យជាជួរដេក និងជួរឈរដូចក្រាបខាងលើ គេហៅថាជាម៉ាទ្រីស ។

២. និយមន័យ និងការកំណត់សរសេរ

និយមន័យ ១.១. គេហៅថាម៉ាទ្រីសមានទំហំ (p,n) ឬ $p\times n$ មានមេគុណក្នុង $\mathbb{K}$ ជាតារាង A មួយរាងចតុកោណកែងមាន pn ធាតុរៀបលើ p ជួរដេក និងលើ n ជួរឈរ៖

$$A=\begin{pmatrix} a_{11} & a_{12} & \cdots & a_{1j} & \cdots & a_{1n}\\ a_{21} & a_{22} & \cdots & a_{2j} & \cdots & a_{2n}\\ \vdots & \cdots & \cdots & \cdots & \cdots & \vdots\\ a_{i1} & a_{i2} & \cdots & a_{ij} & \cdots & a_{in}\\ \vdots & \cdots & \cdots & \cdots & \cdots & \vdots\\ a_{p1} & a_{p2} & \cdots & a_{pj} & \cdots & a_{pn} \end{pmatrix} \tag{១.២}$$

ដែលគេអាចសរសេរយ៉ាងខ្លី $A=(a_{ij})$ (១.៣)

សំណុំនៃម៉ាទ្រីសមាន p ជួរដេក និង n ជួរឈរកំណត់សរសេរដោយ $\mathcal{M}_{p,n}(\mathbb{K})$ ឬ $\mathbb{K}^{p\times n}$ ។

ឧទាហរណ៍ ១.១.

ក. $A=\begin{pmatrix}1 & 2 & 3\\ 0 & 4 & 0\end{pmatrix}$ ជាម៉ាទ្រីសមានទំហំ $(3,2)$ ឬ 3×2 នោះ $A\in\mathcal{M}_{3,2}(\mathbb{R})$ ។

ខ. $B=\begin{pmatrix}3 & 2 & 1\\ 2 & 1 & 2\\ 3 & 0 & 3\end{pmatrix}$ ជាម៉ាទ្រីស មានទំហំ $(3,3)$ ឬ 3×3 នោះ $B\in\mathcal{M}_{3}(\mathbb{R})$

គ. $C=\begin{pmatrix}3-i & 2 & 1\\ 2 & 1 & i+2\\ 3 & i & 3\end{pmatrix}$ ជាម៉ាទ្រីស មានទំហំ $(3,3)$ ឬ 3×3 នោះ $C\in\mathcal{M}_{3}(\mathbb{C})$

ឃ. $D=$ 

មិនមែនជាម៉ាទ្រីសទេ ។

ចំណាំ ១.១. នៅក្នុងការកំណត់សរសេរ a_{ij} សន្ទស្សន៍ទី i សម្គាល់ជួរដេកទី i និងសន្ទស្សន៍ទីពីរ j សម្គាល់ជួរឈរទី j ។

៣. ប្រភេទនៃម៉ាទ្រីស

៣.១. ម៉ាទ្រីសសូន្យ

និយមន័យ ១.២. ម៉ាទ្រីសសូន្យ គឺជាម៉ាទ្រីសទាំងឡាយណាដែលមានធាតុទាំងអ ស់ស្មើសូន្យ ។

ឧទាហរណ៍ ១.២. ខាងក្រោមនេះជាម៉ាទ្រីសសូន្យ

១. $A = (0)$

២. $B = (0, 0, 0)$

៣. $C = \begin{pmatrix} 0 & 0 \\ 0 & 0 \end{pmatrix}$

៤. $D = \begin{pmatrix} 0 & 0 & 0 \\ 0 & 0 & 0 \end{pmatrix}$

៣.២. ម៉ាទ្រីសការេ (Square Matrix)

និយមន័យ ១.៣. ម៉ាទ្រីសការេ គឺជាម៉ាទ្រីសដែលមានលំដាប់ជួរដេកនិងលំដាប់ជួរឈរស្មើគ្នា ។ ម៉ាទ្រីលំដាប់ $n \times n$ ហៅថា ម៉ាទ្រីសការេលំដាប់ n (n-square matrix) ។ តាមនិយមន័យ១.២ បើ $p = n$ នោះ $\mathcal{M}_{n,n}(\mathbb{K})$ ហៅថាម៉ាទ្រីសការេទំហំ n កំណត់សរសេរដោយ $\mathcal{M}_n(\mathbb{K})$ ឬ $\mathbb{K}^{n\times n}$ ។

ឧទាហរណ៍ ១.៣. ១. $A = \begin{pmatrix} 1 & 2 \\ 3 & 4 \end{pmatrix}$ ជាម៉ាទ្រីសការេ មានទំហំ $(2, 2)$ ឬ 2×2 នោះ $B \in \mathcal{M}_2(\mathbb{R})$ ។

២. $B = \begin{pmatrix} -1 & 0 & 1 \\ 2 & 1 & 0 \\ 3 & -2 & 1 \end{pmatrix}$ ជាម៉ាទ្រីសការេ មានទំហំ $(3, 3)$ ឬ 3×3 នោះ $B \in \mathcal{M}_3(\mathbb{R})$ ។

៣. $C = \begin{pmatrix} 1 & 2 & 3 \\ 3 & 4 & 5 \end{pmatrix}$ មិនមែនជាម៉ាទ្រីសការេទេ ព្រោះ មានទំហំ $(2, 3)$ ឬ 2×3 នោះ $C \in \mathcal{M}_{2,3}(\mathbb{R})$ ។

៣.៣. ម៉ាទ្រីសឯកតា

និយមន័យ ១.៤. ម៉ាទ្រីការេ ដែលមានធាតុនៅលើអង្គត់ទ្រូងពិសេស $a_{11} = a_{22} = a_{33} = \cdots = a_{nn} = 1$ ហើយធាតុរផ្សេងទៀតស្មើនឹងសូន្យ ហៅថាម៉ាទ្រីសឯកតា តាងដោយ I ។

ឧទាហរណ៍ ១.៤. គេឲ្យម៉ាទ្រីសខាងក្រោម៖

១. $A = \begin{pmatrix} 1 & 0 \\ 0 & 1 \end{pmatrix}$ ជាម៉ាទ្រីសឯកតា មានលំដាប់ $(2, 2)$ ឬ 2×2 ។

២. $B = \begin{pmatrix} 1 & 0 & 0 \\ 0 & 1 & 0 \\ 0 & 0 & 1 \end{pmatrix}$ ជាម៉ាទ្រីសឯកតា មានលំដាប់ $(3,3)$ ឬ 3×3 ។

៣. $C = \begin{pmatrix} 1 & 0 & 0 & 0 \\ 0 & 1 & 0 & 0 \\ 0 & 0 & 1 & 0 \\ 0 & 0 & 0 & 1 \end{pmatrix}$ ជាម៉ាទ្រីសឯកតា មានលំដាប់ $(4,4)$ ឬ 4×4 ។

៣.៤. ម៉ាទ្រីសបឋម

និយមន័យ ១.៥. A ជាម៉ាទ្រីសការេលំដាប់ $n \times n$ ហៅថាម៉ាទ្រីសបឋមកាលណា A ជាម៉ាទ្រីសដែលបានមកដោយការធ្វើប្រមាណវិធីជួរដេកដំបូងតែមួយគត់លើម៉ាទ្រីសឯកតា I_n ។

ឧទាហរណ៍ ១.៥. គេឲ្យម៉ាទ្រីសឯកតាបីគឺ $I_2 = \begin{pmatrix} 1 & 0 \\ 0 & 1 \end{pmatrix}$; $I_3 = \begin{pmatrix} 1 & 0 & 0 \\ 0 & 1 & 0 \\ 0 & 0 & 1 \end{pmatrix}$ និង $I_4 = \begin{pmatrix} 1 & 0 & 0 & 0 \\ 0 & 1 & 0 & 0 \\ 0 & 0 & 1 & 0 \\ 0 & 0 & 0 & 1 \end{pmatrix}$

ដំណោះស្រាយ

- គេមាន $I_2 = \begin{pmatrix} 1 & 0 \\ 0 & 1 \end{pmatrix}$ យក A ជាម៉ាទ្រីសដែលបានមកពីការគុណជួរដេកទីមួយនៃ I_2 នឹង 3

នោះគេបាន $A = \begin{pmatrix} 3 & 0 \\ 0 & 1 \end{pmatrix} R_1 \to 3R_1$

ដូចនេះ $\boxed{A = \begin{pmatrix} 3 & 0 \\ 0 & 1 \end{pmatrix} \text{ ជាម៉ាទ្រីសបឋម}}$

- គេមាន $I_3 = \begin{pmatrix} 1 & 0 & 0 \\ 0 & 1 & 0 \\ 0 & 0 & 1 \end{pmatrix}$ យក B ជាម៉ាទ្រីសដែលបានមកពីការប្តូរជួរដេកទីពីរ និងជួរដេកទីបីនៃ I_3 នោះ

គេបាន $B = \begin{pmatrix} 1 & 0 & 0 \\ 0 & 0 & 1 \\ 0 & 1 & 0 \end{pmatrix}$

ដូចនេះ $\boxed{B = \begin{pmatrix} 1 & 0 & 0 \\ 0 & 0 & 1 \\ 0 & 1 & 0 \end{pmatrix} \text{ ជាម៉ាទ្រីសបឋម}}$

- គេមាន $I_4 = \begin{pmatrix} 1 & 0 & 0 & 0 \\ 0 & 1 & 0 & 0 \\ 0 & 0 & 1 & 0 \\ 0 & 0 & 0 & 1 \end{pmatrix}$ យក C ជាម៉ាទ្រីសដែលបានមកដោយគុណជួរដេកទីបីនឹង 2 ហើយបូកជួរដេកទីមួយនៃ I_4

នោះ គេបាន $C = \begin{pmatrix} 1 & 0 & 0 & 0 \\ 0 & 1 & 0 & 0 \\ 1 & 0 & 2 & 0 \\ 0 & 0 & 0 & 1 \end{pmatrix} R_3 \to 2R_3 + R_1$

ដូចនេះ $\boxed{C = \begin{pmatrix} 1 & 0 & 0 & 0 \\ 0 & 1 & 0 & 0 \\ 1 & 0 & 2 & 0 \\ 0 & 0 & 0 & 1 \end{pmatrix} \text{ ជាម៉ាទ្រីសបឋម}}$

៣.៥. ម៉ាទ្រីសអង្កត់ទ្រូង (Diagonal Matrix)

និយមន័យ ១.៦. $A = (a_{ij})_{1\le i\le n,1\le j\le n}$ ជាម៉ាទ្រីសការេលំដាប់ $n \times n$ ហៅថាម៉ាទ្រីសអង្កត់ទ្រូង លុះត្រាតែគ្រប់ធាតុ ដែលមិនមែនជាធាតុនៃអង្កត់ទ្រូងពិសេសសុទ្ធតែស្មើសូន្យ និងគ្រប់ធាតុដែលជាធាតុនៃអង្កត់ទ្រូង ពិសេសខុសពីសូន្យ ។ មានន័យថា $a_{ij} = 0, \forall i \ne j; a_{ij} \ne 0, \forall i = j$ គេសរសេរ $A = \begin{pmatrix} a_{11} & 0 & \cdots & 0 \\ 0 & a_{22} & \cdots & 0 \\ \vdots & \vdots & \ddots & \vdots \\ 0 & 0 & \cdots & a_{nn} \end{pmatrix}; a_{11}, a_{22}, \cdots, a_{nn} \ne 0$ ។

ចំណាំ ១.២. បើ $a_{11} = a_{22} = \cdots = a_{nn} = 1$ នោះ A ក្លាយជាម៉ាទ្រីសឯកតា ។

ឧទាហរណ៍ ១.៦. តើក្នុងចំណោមម៉ាទ្រីសខាងក្រោមមួយណាខ្លះជាម៉ាទ្រីសអង្កត់ទ្រូង៖

ក . $A = \begin{pmatrix} 1 & 0 & 0 \\ 0 & 2 & 0 \\ 0 & 0 & 3 \end{pmatrix}$ ខ . $B = \begin{pmatrix} -1 & 0 & 0 \\ 0 & 3 & 0 \\ 0 & 0 & -1 \end{pmatrix}$ គ . $C = \begin{pmatrix} 1 & 0 & 1 \\ 0 & -2 & 0 \\ 0 & 0 & 0 \end{pmatrix}$ ។

ដំណោះស្រាយ

ក . A ជាម៉ាទ្រីសអង្កត់ទ្រូង ។

ខ . B ជាម៉ាទ្រីសអង្កត់ទ្រូង ។

គ . C មិនមែនជាម៉ាទ្រីសអង្កត់ទ្រូងទេព្រោះ $a_{33} = 0$ ។

៣.៦. ម៉ាទ្រីសត្រីកោណលើ

និយមន័យ ១.៧. A ជាម៉ាទ្រីសមួយហៅថាម៉ាទ្រីសត្រីកោណលើ បើគ្រប់ធាតុទាំងអស់ដែលឋិតនៅខាងក្រោមអង្កត់ទ្រូងសំខាន់ គឺស្មើសូន្យទាំងអស់ ។ គេអាចសរសេរទម្រង់ទូទៅ៖ $A = \begin{pmatrix} a_{11} & a_{12} & \cdots & a_{1n} \\ 0 & a_{22} & \cdots & a_{2n} \\ \vdots & \vdots & \ddots & \vdots \\ 0 & 0 & \cdots & a_{nn} \end{pmatrix}$

មានន័យថា៖ $A = (a_{ij})_{1\le i\le n,1\le j\le n}$ ដែល $a_{ij} = 0, \forall i > j$; $a_{ij} \ne 1, \forall i = j$ និង $\exists a_{ij} \ne 0, i < j$ ។

ឧទាហរណ៍ ១.៧. ម៉ាទ្រីសត្រីកោណលើ៖

ក. $A=\begin{pmatrix}1 & 2\\0 & 3\end{pmatrix}$ ខ. $A=\begin{pmatrix}1 & 2 & 3\\0 & 3 & 0\\0 & 0 & -1\end{pmatrix}$ គ. $A=\begin{pmatrix}a_{11} & a_{12} & a_{13} & a_{14}\\0 & a_{22} & a_{23} & a_{34}\\0 & 0 & a_{33} & a_{34}\\0 & 0 & 0 & a_{44}\end{pmatrix}$

៣.៧. ម៉ាទ្រីសត្រីកោណក្រោម

និយមន័យ ១.៨. ម៉ាទ្រីសមួយហៅថាម៉ាទ្រីសត្រីកោណក្រោម បើគ្រប់ធាតុទាំងអស់ដែលស្ថិតនៅខាងលើអង្កត់ទ្រូងសំខាន់ គឺស្មើសូន្យទាំងអស់ ។ គេអាចសរសេរទម្រង់ទូទៅ៖ $\begin{pmatrix}a_{11} & 0 & \cdots & 0\\a_{21} & a_{22} & \cdots & 0\\\vdots & \vdots & \ddots & \vdots\\a_{n1} & a_{n2} & \cdots & a_{nn}\end{pmatrix}$

មានន័យថា៖ $A=(a_{ij})_{1\le i\le n,1\le j\le n}$ ដែល $a_{ij}=0,\forall i<j$; $a_{ij}\neq 0,\forall i=j$ និង $\exists a_{ij}\neq 0, i>j$ ។

ឧទាហរណ៍ ១.៨. ម៉ាទ្រីសត្រីកោណក្រោម៖

$A=\begin{pmatrix}1 & 0\\2 & 3\end{pmatrix}$ $A=\begin{pmatrix}1 & 0 & 0\\2 & 3 & 0\\-1 & 0 & 4\end{pmatrix}$ $A=\begin{pmatrix}a_{11} & 0 & 0 & 0\\a_{21} & a_{22} & 0 & 0\\a_{31} & a_{32} & a_{33} & 0\\a_{41} & a_{42} & a_{43} & a_{44}\end{pmatrix}$

៣.៨. ម៉ាទ្រីសឆ្លុះ ឬម៉ាទ្រីសស៊ីមេទ្រី

ឧទាហរណ៍ ១.៩. $A=(a_{ij})$ ដែល $1\le i\le n, 1\le j\le n$ ជាម៉ាទ្រីសការេលំដាប់ $n\times n$ ហៅថាម៉ាទ្រីសឆ្លុះ ឬម៉ាទ្រីសស៊ីមេទ្រី កាលណាត្រង់ស្ប៉ូសេ $TRANSPOSE$ នៃម៉ាទ្រីស A ស្មើនឹងម៉ាទ្រីស A ។ មានន័យថា $A^T=A$

ឧទាហរណ៍ ១.១០. គេឲ្យម៉ាទ្រីស $A=\begin{pmatrix}1 & 2 & 3\\2 & 4 & 5\\3 & 5 & 6\end{pmatrix}\Rightarrow A^T=\begin{pmatrix}1 & 2 & 3\\2 & 4 & 5\\3 & 5 & 6\end{pmatrix}$

ដោយ $A=A^T$ នោះ A ជាម៉ាទ្រីសស៊ីមេទ្រី ។

ចំណាំ ១.៣. ម៉ាទ្រីសការេ A ជាម៉ាទ្រីសប្រាសស៊ីមេទ្រីលុះត្រាតែ $A^T=A$ នោះបានលក្ខណៈខាងក្រោម៖

- បើ A ជាម៉ាទ្រីសការេនោះ $A+A^T$ ជាម៉ាទ្រីសឆ្លុះ ។
- បើ A ជាម៉ាទ្រីសការេនោះ $A-A^T$ ជាម៉ាទ្រីសប្រាសស៊ីមេទ្រី ។

៣.៩. ម៉ាទ្រីសកែង

និយមន័យ ១.៩. $A=(a_{ij})$ ដែល $1\le i\le n, 1\le j\le n$ ជាម៉ាទ្រីសការេលំដាប់ $n\times n$ គឺជាម៉ាទ្រីសកែង កាលណា ចម្រាសរបស់វាស្មើនឹងម៉ាទ្រីសត្រង់ស្ប៉ូសេរបស់វា ។

ចំណាំ ១.៤. បើ A ជាម៉ាទ្រីសកែង នោះ $A^{-1}=A^T$ នាំឲ្យ $AA^{-1}=AA^T=I_n$ ដែល I_n ជាម៉ាទ្រីសឯកតា ។
ដូចនេះ A ជាម៉ាទ្រីសកែងកាលណា $A^{-1}=A^T$ ឬ $AA^T=A^TA=I_n$ ។

ឧទាហរណ៍ ១.១១. គេឲ្យម៉ាទ្រីស $A=\begin{pmatrix}\cos\theta & -\sin\theta\\ \sin\theta & \cos\theta\end{pmatrix}\Rightarrow A^T=\begin{pmatrix}\cos\theta & \sin\theta\\ -\sin\theta & \cos\theta\end{pmatrix}$

គេបាន $B^T=\begin{pmatrix}\cos\theta & -\sin\theta\\ \sin\theta & \cos\theta\end{pmatrix}\begin{pmatrix}\cos\theta & \sin\theta\\ -\sin\theta & \cos\theta\end{pmatrix}$

$$=\begin{pmatrix}\cos^2\theta+\sin^2\theta & \cos\theta\sin\theta-\sin\theta\cos\theta\\ \sin\theta & \cos\theta\end{pmatrix}$$

$$=\begin{pmatrix}\cos^2\theta+\sin^2\theta & \cos\theta\sin\theta-\sin\theta\cos\theta\\ \sin\theta\cos\theta-\cos\theta\sin\theta & \sin^2\theta+\cos^2\theta\end{pmatrix}$$

$$=\begin{pmatrix}1 & \sin 0\\ \sin 0 & 1\end{pmatrix}=\begin{pmatrix}1 & 0\\ 0 & 1\end{pmatrix}$$

$AA^T=I_2$

ដូចនេះ $\boxed{A \text{ ជាម៉ាទ្រីសកែង}}$

៣.១០. ប្រមាណវិធីបូកម៉ាទ្រីស

នៅលើសំណុំ $\mathcal{M}_{p,n}(\mathbb{K})$ គេកំណត់ប្រមាណវិធី៖

ចំពោះ $A=(a_{ij})$ និង $B=(b_{ij})$ គេបាន $A+B=[a_{ij}+b_{ij}]\ ,(i=\overline{1,p}\,;j=\overline{1,n})$

ឧទាហរណ៍ ១.១២. គេមានម៉ាទ្រីស $A=\begin{pmatrix}5 & 1\\ 7 & 3\\ -2 & -1\end{pmatrix}$ $,B=\begin{pmatrix}-6 & 3\\ 2 & -1\\ 4 & 1\end{pmatrix}$ និង $C=\begin{pmatrix}2 & 1\\ 0 & 3\end{pmatrix}$

គណនា $$A+B=\begin{pmatrix}5 & 1\\ 7 & 3\\ -2 & -1\end{pmatrix}+\begin{pmatrix}-6 & 3\\ 2 & -1\\ 4 & 1\end{pmatrix}$$
$$=\begin{pmatrix}5-6 & 1+3\\ 7+2 & 3-1\\ -2+4 & -1+1\end{pmatrix}$$
$$\therefore\quad A+B=\begin{pmatrix}-1 & 4\\ 9 & 2\\ 2 & 0\end{pmatrix}$$

គណនា $A+C$ មិនអាចបូកបានទេព្រោះ ម៉ាទ្រីសទាំងពីរមានលំដាប់ខុសគ្នា ។

Listing ១.1: ដោះស្រាយតាម matlab

```
a = [5 1 ; 7 3 ; -2 -1];
b = [-6 3 ; 2 -1 ; 4 1];
c = [2 1 ; 0 3];
q1 = a+b
q2 = a+c
```

ទ្រឹស្តីបទ ១.១. បើ A,B និង C ជាម៉ាទ្រីសមានលំដាប់ស្មើគ្នា នោះគេបាន៖

១. លក្ខណៈត្រឡប់ចំពោះប្រមាណវិធីបូក៖ គេបាន $A+B=B+A$ ។

២. លក្ខណៈផ្តុំចំពោះប្រណាណវិធីបូក៖ គេបាន $A+(B+C)=(A+B)+C$ ។

សម្រាយបញ្ជាក់

តាង $A=[a_{ij}],B=[b_{ij}]$ និង $C=[c_{ij}]$

១. គេបាន $$A+B=[a_{ij}]+[b_{ij}]$$
$$=[a_{ij}+b_{ij}]$$
$$=[b_{ij}+b_{ij}]$$
$$=[b_{ij}]+[a_{ij}]$$
$$\therefore\quad A+B=B+A$$

២. គេបាន
$$\begin{aligned} A+(B+C) &= [a_{ij}]+([b_{ij}]+[c_{ij}]) \\ &= [a_{ij}]+([b_{ij}+c_{ij}]) \\ &= [a_{ij}+(b_{ij}+c_{ij}) \\ &= [(a_{ij}+b_{ij})+c_{ij}] \\ &= [(a_i+b_{ij})]+[c_{ij}] \\ &= ([a_{ij}]+[b_{ij}])+[c_{ij}] \end{aligned}$$
$$\therefore \quad A+(B+C)=(A+B)+C$$

លក្ខណៈ ១.១. ចំពោះ ម៉ាទ្រីស A ធ្វើប្រមាណវិធីនឹងម៉ាទ្រីស 0 គេបាន $A+0=A$ ។

ឧទាហរណ៍ ១.១៣. គេឲ្យម៉ាទ្រីស $A=\begin{pmatrix}1&2&3\\4&5&6\\7&8&9\end{pmatrix}$ និង $B=\begin{pmatrix}2&1&3\\5&2&2\\-1&3&1\end{pmatrix}$ ។ គណនា $A+B$ និង $A-B$ ។

គេបាន
$$A+B=\begin{pmatrix}1&2&3\\4&5&6\\7&8&9\end{pmatrix}+\begin{pmatrix}2&1&3\\5&2&2\\-1&3&1\end{pmatrix}=\begin{pmatrix}1+2&2+1&3+3\\4+5&5+2&6+2\\7-1&8+3&9+1\end{pmatrix}$$
$$\therefore \quad A+B=\begin{pmatrix}3&3&6\\9&7&8\\6&11&10\end{pmatrix}$$
$$A-B=\begin{pmatrix}1&2&3\\4&5&6\\7&8&9\end{pmatrix}-\begin{pmatrix}2&1&3\\5&2&2\\-1&3&1\end{pmatrix}=\begin{pmatrix}1-2&2-1&3-3\\4-5&5-2&6-2\\7+1&8-3&9-1\end{pmatrix}$$
$$\therefore \quad A-B=\begin{pmatrix}-1&1&0\\-1&3&4\\8&5&8\end{pmatrix}$$

Listing ១.2: ដោះស្រាយតាម matlab

```
clear all
a = [1 2 3 ; 4 5 6 ; 7 8 9];
b = [2 1 3 ; 5 2 2 ; -1 3 1];
q1 = a+b
q2 = a-b
```

ទ្រឹស្តីបទ ១.២. បើ A និង B ជាម៉ាទ្រីមានលំដាប់ដូចគ្នា និង $\lambda_1, \lambda_2 \in \mathbb{R}$ នោះគេបាន៖

១. $\lambda_1(A+B) = \lambda_1 A + \lambda_1 B$

២. $(\lambda_1 + \lambda_2)A = \lambda_1 A + \lambda_2 A$

៣. $(\lambda_1\lambda_2)A = \lambda_1(\lambda_2 A)$

សម្រាយបញ្ជាក់

តាង $A = [a_{ij}]$ និង $B = [b_{ij}]$

១. ចំពោះ $\lambda_1 \in \mathbb{R}$ គេបាន
$$\begin{aligned}\lambda_1(A+B) &= \lambda_1\left([a_{ij}] + [b_{ij}]\right)\\ &= \lambda_1\left[(a_{ij}+b_{ij})\right]\\ &= \left[(\lambda_1 a_{ij} + \lambda_1 b_{ij})\right]\\ &= [\lambda_1 a_{ij}] + [\lambda_1 b_{ij}]\\ &= \lambda_1[a_{ij}] + \lambda_1[b_{ij}]\\ \therefore \quad \lambda_1(A+B) &= \lambda_1 A + \lambda_1 B\end{aligned}$$

២. ចំពោះ $\lambda_1, \lambda_2 \in \mathbb{R}$ គេបាន
$$\begin{aligned}(\lambda_1+\lambda_2)A &= (\lambda_1+\lambda_2)[a_{ij}]\\ &= \lambda_1[a_{ij}] + \lambda_2[a_{ij}]\\ \therefore \quad (\lambda_1+\lambda_2)A &= \lambda_1 A + \lambda_2 A\end{aligned}$$

៣. ចំពោះ $\lambda_1, \lambda_2 \in \mathbb{R}$ គេបាន
$$\begin{aligned}(\lambda_1\lambda_2)A &= (\lambda_1\lambda_2)[a_{ij}]\\ &= \lambda_1(\lambda_2[a_{ij}])\\ \therefore \quad (\lambda_1\lambda_2)A &= \lambda_1(\lambda_2 A)\end{aligned}$$

ឧទាហរណ៍ ១.១៤. គេឲ្យម៉ាទ្រី $A = \begin{pmatrix} 1 & 2 \\ 3 & 4 \end{pmatrix}$, $B = \begin{pmatrix} 5 & 6 \\ 7 & 8 \end{pmatrix}$, $C = \begin{pmatrix} -1 & 0 \\ 3 & -3 \end{pmatrix}$ ។
គណនា $2A$, $A+B$, $3(A-B)$, $2A+3B$ និង $A+B+C$ ។

ដំណោះស្រាយ

- $2A = 2\begin{pmatrix} 1 & 2 \\ 3 & 4 \end{pmatrix} = \begin{pmatrix} 2 & 4 \\ 6 & 8 \end{pmatrix}$

- $A+B = \begin{pmatrix} 1 & 2 \\ 3 & 4 \end{pmatrix} + \begin{pmatrix} 5 & 6 \\ 7 & 8 \end{pmatrix} = \begin{pmatrix} 1+5 & 2+6 \\ 3+7 & 4+8 \end{pmatrix} = \begin{pmatrix} 6 & 8 \\ 10 & 12 \end{pmatrix}$

- $$\begin{aligned} 3(A-B) = 3A - 3B &= 3\begin{pmatrix} 1 & 2 \\ 3 & 4 \end{pmatrix} - 3\begin{pmatrix} 5 & 6 \\ 7 & 8 \end{pmatrix} \\ &= \begin{pmatrix} 3 & 6 \\ 9 & 12 \end{pmatrix} - \begin{pmatrix} 15 & 18 \\ 21 & 24 \end{pmatrix} \\ &= \begin{pmatrix} 3-15 & 6-18 \\ 9-21 & 12-24 \end{pmatrix} \\ &= \begin{pmatrix} -12 & -12 \\ -12 & -12 \end{pmatrix} \end{aligned}$$

- $$\begin{aligned} 2A+3B = 2A+2B+B = 2(A+B)+B &= 2\begin{pmatrix} 6 & 8 \\ 10 & 12 \end{pmatrix} + \begin{pmatrix} 5 & 6 \\ 7 & 8 \end{pmatrix} \\ &= \begin{pmatrix} 12 & 16 \\ 20 & 24 \end{pmatrix} + \begin{pmatrix} 5 & 6 \\ 7 & 8 \end{pmatrix} \\ &= \begin{pmatrix} 12+5 & 16+6 \\ 20+7 & 24+8 \end{pmatrix} \\ &= \begin{pmatrix} 17 & 22 \\ 27 & 32 \end{pmatrix} \end{aligned}$$

- $$\begin{aligned} A+B+C = (A+B)+C &= \begin{pmatrix} 6 & 8 \\ 10 & 12 \end{pmatrix} + \begin{pmatrix} -1 & 0 \\ 3 & -3 \end{pmatrix} \\ &= \begin{pmatrix} 6-1 & 8+0 \\ 10+3 & 12-3 \end{pmatrix} \\ &= \begin{pmatrix} 5 & 8 \\ 13 & 9 \end{pmatrix} \end{aligned}$$

Listing ១.3: ដំណោះស្រាយតាម matlab

```
clear all
a = [1 2 ; 3 4];
b = [5 6 ; 7 8];
c = [-1 0 ; 3 -3];
q1 = 2.*a
```

```
q2 = a+b
q3 = 3.*(a-b)
q4 = 2.*a+3.*b
q5 = a+b+c
```

៣.១១. ប្រមាណវិធីគុណម៉ាទ្រីស

បើគេមានប្រព័ន្ធសមីការដឺក្រេទីមួយមានបីអញ្ញាតដូចខាងក្រោម៖

$$\begin{cases} x+2y+3z &= 4 \\ 5x+6y+7z &= 8 \\ -1x-2y-3z &= 9 \end{cases} \tag{១.៤}$$

គេអាចសរសេរប្រព័ន្ធសមីការ (១.៤) ជាទំរង់ [ចំនួនថេរ].[អថេរ] = ចំនួនថេរ

គេបាន

$$\begin{pmatrix} 1 & 2 & 3 \\ 5 & 6 & 7 \\ -1 & -2 & -3 \end{pmatrix} \cdot \begin{pmatrix} x \\ y \\ z \end{pmatrix} = \begin{pmatrix} 4 \\ 8 \\ 9 \end{pmatrix} \tag{១.៥}$$

តាមប្រព័ន្ធសមីការ (១.៤) និង (១.៥) គេអាចកំណត់ផលគុណនៃម៉ាទ្រីសបាន៖

$$\begin{pmatrix} 1 & 2 & 3 \\ 5 & 6 & 7 \\ -1 & -2 & -3 \end{pmatrix} \cdot \begin{pmatrix} x \\ y \\ z \end{pmatrix} = \begin{pmatrix} 1x+2y+3y \\ 5x+6y+7z \\ -1x-2y-3 \end{pmatrix} \tag{១.៦}$$

និយមន័យ ១.១០. ផលគុណនៃម៉ាទ្រីស ជាអនុវត្តន៍

$$\begin{aligned} \mathcal{M}_{p,n}(\mathbb{K}) \times \mathcal{M}_{n,q}(\mathbb{K}) &\longrightarrow \mathcal{M}_{p,q}(\mathbb{K}) \\ ([a_{ij}],[b_{ij}]) &\longmapsto [c_{ik}] \end{aligned} \tag{១.៧}$$

ដែល $$c_{ik} = a_{i1}b_{1k} + a_{i2}b_{2k} + \cdots + a_{in}b_{nk} = \sum_{j=1}^{n} a_{ij}b_{jk} \tag{១.៨}$$

ដូច្នេះធាតុ c_{ik} នៃជួរដេកទី i និងជួរឈរទី k នៃផលគុណ $C = AB$ ជាផលបូកនៃផលគុណនៃធាតុនៃម៉ាទ្រីសផលគុណ $C = AB$ ត្រូវបានចាត់ទុកដូចផលគុណស្កាលែនៃវ៉ិចទ័រជួរដេកទី i នៃម៉ាទ្រីសទីមួយនិង A និង វ៉ិចទ័រជួរឈរទី k នៃម៉ាទ្រីសទីពីរ B ។ មានន័យថា ផលគុណនៃពីរម៉ាទ្រីសត្រូវធ្វើ ជួរដេកជាមួយជួរឈរ ។

ចំណាំ ១.៥. ម៉ាទ្រីសពីរធ្វើប្រមាណវិធីគុណបាន កាលណាចំនួនជួរឈរនៃម៉ាទ្រីសទី១ ស្មើនឹងចំនួនជួរដេកនៃទីពីរ ។

ឧទាហរណ៍ ១.១៥. គេឲ្យ $A = \begin{pmatrix} 1 & 2 & 3 \\ 4 & 5 & 6 \end{pmatrix}$, $B = \begin{pmatrix} -7 & -8 \\ 9 & 10 \\ 0 & -11 \end{pmatrix}$ និង $C = \begin{pmatrix} 2 & 3 \\ 3 & 2 \end{pmatrix}$ ។

គណនា AB , BA , AC និង CA ។ រួចទាញថា $AB \neq BA$ ។

ដំណោះស្រាយ

គេបាន $$AB = \begin{pmatrix} 1 & 2 & 3 \\ 4 & 5 & 6 \end{pmatrix} \cdot \begin{pmatrix} -7 & -8 \\ 9 & 10 \\ 0 & -11 \end{pmatrix}$$

$$= \begin{pmatrix} (1)(-7)+(2)(9)+(3)(0) & (1)(-8)+(2)(10)+(3)(-11) \\ (4)(-7)+(5)(9)+(6)(0) & (4)(-8)+(5)(10)+(6)(-11) \end{pmatrix}$$

$$\therefore \quad AB = \begin{pmatrix} 11 & -21 \\ 17 & -48 \end{pmatrix} \quad (I)$$

$$BA = \begin{pmatrix} -7 & -8 \\ 9 & 10 \\ 0 & -11 \end{pmatrix} \cdot \begin{pmatrix} 1 & 2 & 3 \\ 4 & 5 & 6 \end{pmatrix}$$

$$= \begin{pmatrix} (-7)(1)+(-8)(4) & (-7)(2)+(-8)(5) & (-7)(3)+(-8)(6) \\ (9)(1)+(10)(4) & (9)(2)+(10)(5) & (9)(3)+(10)(6) \\ (0)(1)+(-11)(4) & (0)(2)+(-11)(5) & (0)(3)+(-11)(6) \end{pmatrix}$$

$$\therefore \quad BA = \begin{pmatrix} -39 & -54 & -69 \\ 49 & 68 & 87 \\ -44 & -55 & -66 \end{pmatrix} \quad (II)$$

ចំពោះ AC តាមនិយមន័យមិនអាចគុណបានទេ ព្រោះ A ជាម៉ាទ្រីសលំដាប់ (2×3) ហើយ C ជាម៉ាទ្រីសលំដាប់ (2×2) ។ តែ CA គេអាចគណនាបាន ព្រោះ C ជាម៉ាទ្រីសលំដាប់ (3×2) និង A ជាម៉ាទ្រីសលំដាប់ (2×2)

គេបាន $$CA = \begin{pmatrix} 2 & 3 \\ 3 & 2 \end{pmatrix} \begin{pmatrix} 1 & 2 & 3 \\ 4 & 5 & 6 \end{pmatrix}$$

$$= \begin{pmatrix} (2)(1)+(3)(4) & (2)(2)+(5)(3) & (2)(3)+(3)(6) \\ (3)(1)+(2)(4) & (3)(2)+(2)(5) & (3)(3)+(2)(6) \end{pmatrix}$$

$$= \begin{pmatrix} 14 & 19 & 24 \\ 11 & 16 & 21 \end{pmatrix}$$

តាម (I) និង (II) គេបាន $AB \neq BA$

Listing ១.4: ដោះស្រាយតាម matlab

```
clear all
a = [1 2 3 ; 4 5 6];
b = [-7 -8 ; 9 10 ; 0 -11];
c = [2 3 ; 3 2];
q1 = a*b
q2 = b*a
q3 = a*c
q4 = c*a
```

ទ្រឹស្តីបទ ១.៣. បើ A, B និង C គឺជាបីម៉ាទ្រីសមានលំដាប់ដូចគ្នា នោះគេបាន៖

១. $A(BC) = (AB)C$ លក្ខណៈផ្តុំចំពោះប្រមាណវិធីគុណ

២. $A(B+C) = AB + AC$ លក្ខណៈបំបែកខាងឆ្វេងចំពោះប្រមាណវិធីគុណ

៣. $(B+C)A = BA + CA$ លក្ខណៈបំបែកខាងស្តាំចំពោះប្រមាណវិធីគុណ

<u>ដំណោះស្រាយ</u>

បើគេយក $A = [a_{ij}], B = [b_{ij}]$ ជាម៉ាទ្រីសលំដាប់ $m \times n$ និង $C = [c_{ij}]$ ជាម៉ាទ្រីសលំដាប់ $n \times p$

១. គេបាន
$$\begin{aligned} A(BC) &= [a_{ij}]\left([b_{ij}][c_{ij}]\right) \\ &= [a_{ij}][b_{ij}][c_{ij}] \\ &= \left([a_{ij}][b_{ij}]\right)[c_{ij}] \\ \therefore \quad A(BC) &= (AB)C \end{aligned}$$

២. គេបាន
$$\begin{aligned} A(B+C) &= [a_{ij}]\left([b_{ij}]+[c_{ij}]\right)\\ &= [a_{ij}]\left[(b_{ij}+c_{ij})\right]\\ &= \left[\sum_{k=1}^{n} a_{ik}(b_{kj}+c_{kj})\right]\\ &= \left[\sum_{k=1}^{n}(a_{ik}b_{kj}+a_{ik}c_{kj})\right]\\ &= \left[\sum_{k=1}^{n} a_{ik}b_{kj}+\sum_{k=1}^{n} a_{ik}c_{kj}\right]\\ &= \left[\sum_{k=1}^{n} a_{ik}b_{kj}\right]+\left[\sum_{k=1}^{n} a_{ik}c_{kj}\right]\\ &= [a_{ij}][b_{ij}]+[a_{ij}][c_{ij}] \quad \text{តាមនិយមន័យ}\\ \therefore\quad A(B+C) &= AB+AC \end{aligned}$$

៣. ស្រាយដូចទី២

៤. ម៉ាទ្រីសច្រាស

និយមន័យ ១.១១. A ជាម៉ាទ្រីសការេមួយដែល $\det(A)\neq 0$ ។ បើគេគុណម៉ាទ្រីស A និងម៉ាទ្រីសការេ B មួយ ហើយ ផលគុណនៃម៉ាទ្រីសនោះជាម៉ាទ្រីសឯកតា $AB=BA=I$ នោះគេថាម៉ាទ្រីស A មានចម្រាស ដែល B ជាចម្រាស ឬជាម៉ាទ្រីសច្រាសនៃ A ។ គេកំណត់សរសេរដោយ $B=A^{-1}$ ដូចនេះគេបាន $AA^{-1}=A^{-1}A=I$ ។

ឧទាហរណ៍ ១.១៦. ម៉ាទ្រីស $B=\begin{bmatrix}-2 & 1\\ 1.5 & -0.5\end{bmatrix}$ គឺជាចម្រាសនៃម៉ាទ្រីស $A=\begin{bmatrix}1 & 2\\ 3 & 4\end{bmatrix}$

ព្រោះ $AB=\begin{bmatrix}1 & 2\\ 3 & 4\end{bmatrix}\begin{bmatrix}-2 & 1\\ 1.5 & -0.5\end{bmatrix}=\begin{bmatrix}1 & 0\\ 0 & 1\end{bmatrix}=\begin{bmatrix}-2 & 1\\ 1.5 & -0.5\end{bmatrix}\begin{bmatrix}1 & 2\\ 3 & 4\end{bmatrix}=BA$

គេសរសេរបាន $A^{-1}=\begin{bmatrix}1 & 2\\ 3 & 4\end{bmatrix}^{-1}=\begin{bmatrix}-2 & 1\\ 1.5 & -0.5\end{bmatrix}$

ឧទាហរណ៍ ១.១៧. គេឲ្យបីម៉ាទ្រីស $A=\begin{pmatrix}4 & 3\\ 3 & 2\end{pmatrix}$, $B=\begin{pmatrix}-2 & 3\\ 3 & -4\end{pmatrix}$ និង $C=\begin{pmatrix}2 & 3\\ 1 & 2\end{pmatrix}$

• បើ $AB = \begin{pmatrix} 4 & 3 \\ 3 & 2 \end{pmatrix}\begin{pmatrix} -2 & 3 \\ 3 & -4 \end{pmatrix} = \begin{pmatrix} (4)(-2)+(3)(3) & (4)(3)+(3)(-4) \\ (3)(-2)+(2)(3) & (3)(3)+(2)(-4) \end{pmatrix}$

$= \begin{pmatrix} 1 & 0 \\ 0 & 1 \end{pmatrix}$

និង $BA = \begin{pmatrix} -2 & 3 \\ 3 & -4 \end{pmatrix}\begin{pmatrix} 4 & 3 \\ 3 & 2 \end{pmatrix} = \begin{pmatrix} (4)(-2)+(3)(3) & (4)(3)+(3)(-4) \\ (3)(-2)+(2)(3) & (3)(3)+(2)(-4) \end{pmatrix}$

$= \begin{pmatrix} 1 & 0 \\ 0 & 1 \end{pmatrix}$

គេបាន $AB = BA = I$ នោះ B ជាចម្រាសនៃម៉ាទ្រីស A ឬ A ជាចម្រាសនៃម៉ាទ្រីស B ។

• បើ $AC = \begin{pmatrix} 4 & 3 \\ 3 & 2 \end{pmatrix}\begin{pmatrix} 2 & 3 \\ 1 & 2 \end{pmatrix} = \begin{pmatrix} 4\times 2+3\times 1 & 4\times 3+3\times 2 \\ 3\times 2+2\times 1 & 3\times 3+2\times 2 \end{pmatrix} = \begin{pmatrix} 7 & 18 \\ 8 & 13 \end{pmatrix}$

គេបាន $AC \neq I_2$ នោះ C មិនមែនជាម៉ាទ្រីសប្រាសនៃម៉ាទ្រីស A ទេ ឬម៉ាទ្រីស A មិនមែនជាម៉ាទ្រីសប្រាសនៃម៉ាទ្រីស B ទេ ។

ទ្រឹស្តីបទ ១.៤. បើពីរម៉ាទ្រីសការេ B និង C ជាម៉ាទ្រីសប្រាសនៃម៉ាទ្រីសការេ A នោះ $B = C$ ។

ដំណោះស្រាយ

បើ B និង C ជាម៉ាទ្រីសប្រាសនៃម៉ាទ្រីស A នោះ $AB = I$ និង $CA = I$

គេបាន $AB = I \Rightarrow C(AB) = CI = C$

$CA = I \Rightarrow (CA)B = IB = B$

ដោយ $C(AB) = (CA)B \Rightarrow C = B$

ទ្រឹស្តីបទ ១.៥. បើពីរម៉ាទ្រីសការេ A និង B ជាម៉ាទ្រីសមានប្រាសដែលមានលំដាប់ដូចគ្នាគេបាន៖

១. ម៉ាទ្រីសការេ AB មានចម្រាស

២. $(AB)^{-1} = B^{-1}A^{-1}$

ដំណោះស្រាយ

គេគ្រាន់តែបង្ហាញថា $(AB)(B^{-1}A^{-1}) = (B^{-1}A^{-1})(AB) = I$ តាមលក្ខណៈប្រមាណវិធីនៃម៉ាទ្រីស

គេបាន $(AB)(B^{-1}A^{-1}) = A(BB^{-1})A^{-1} = AIA^{-1} = AA^{-1} = I$

$(B^{-1}A^{-1})(AB) = B^{-1}(A^{-1}A)B = B^{-1}IB = B^{-1}B = I$

នាំឲ្យ $(AB)(B^{-1}A^{-1}) = (B^{-1}A^{-1})(AB) = I$ មានន័យថាម៉ាទ្រីស AB មានចម្រាសគឺ B^1A^{-1} និងប្រាសមកវិញ ម៉ាទ្រីស $B^{-1}A^{-1}$ មានចម្រាសគឺម៉ាទ្រីស AB ។

ដូចនេះ $(AB)^{-1} = B^{-1}A^{-1}$ ។

៤.១. លក្ខណៈនៃម៉ាទ្រីសច្រាស

1. $(A^{-1})^{-1} = A$
2. $(A^T)^{-1} = (A^{-1})^T$
3. $(kA)^{-1} = \dfrac{1}{k}A^{-1}, k \neq 0$
4. $(AB)^{-1} = B^{-1}A^{-1}$
5. $(ABC)^{-1} = C^{-1}B^{-1}A^{-1}$
6. $(A_1A_2\cdots A_{k-1}A_k)^{-1} = A_k^{-1}A_{k-1}^{-1}\cdots A_2^{-1}A_1^{-1}$
7. $(A^n)^{-1} = (A^{-1})^n \quad , n = 1, 2, 3, \cdots$

៤.២. ដេទែមីណាង់ Determinent

និយមន័យ ១.១២. ដេទែមីណង់ជាអនុគមន៍ដែលយកតម្លៃពិតនៃអថេរដែលមានរាងជាម៉ាទ្រីសការេមួយ ។ មានន័យថាវានឹងកំណត់បាននូវតម្លៃពិត $f(x)$ មួយតាមតម្លៃនៃម៉ាទ្រីសការេ X ។

និយមន័យ ១.១៣. A ជាម៉ាទ្រីការេមួយ ។ អនុគមន៍ដេទែមីណង់តាងដោយ det ឬ $|\quad|$ ហើយអនុគមន៍ដេទែមីណង់នៃ A កំណត់ដោយ $\det(A)$ ឬ $|A|$ គឺជាផលបូកនៃគ្រប់ផលគុណដំបូងដែលមានសញ្ញាទាំងអស់នៃម៉ាទ្រីសការេ A ។

ចំណាំ ១.៦. ផលគុណដំបូងនៃម៉ាទ្រីសការេ A មានន័យថាជាផលគុណណាមួយនៃ n ធាតុរបស់ម៉ាទ្រីស តែគ្មានធាតុពីរណាដែលឋិតក្នុងជួរដេកតែមួយឬ ជួឈរតែមួយទេ ។

ឧទាហរណ៍ ១.១៨. ចូរសរសេរគ្រប់ផលគុណដំបូងទាំងអស់នៃម៉ាទ្រីសការេ ហើយសរសេរគ្រប់ផលគុណដំបូងដែលមានសញ្ញាទាំងអស់នៃម៉ាទ្រីស និងកំណត់ដេទែមីណង់ នៃម៉ាទ្រីសខាងក្រោម៖

១. $A = \begin{pmatrix} a_{11} & a_{12} \\ a_{21} & a_{22} \end{pmatrix}$

២. $A = \begin{pmatrix} a_{11} & a_{12} & a_{13} \\ a_{21} & a_{22} & a_{23} \\ a_{31} & a_{32} & a_{33} \end{pmatrix}$

ដំណោះស្រាយ

១. $A = \begin{pmatrix} a_{11} & a_{12} \\ a_{21} & a_{22} \end{pmatrix}$ ផលគុណដំបូងទាំងអស់នៃម៉ាទ្រីស A មាន $a_{11}a_{22}$ និង $a_{21}a_{12}$

ផលគុណដំបូងដែលមានសញ្ញាទាំងអស់នៃម៉ាទ្រីស A គឺ $a_{11}a_{22}$ និង $-a_{21}a_{12}$

ដូចនេះ $\det(A) = \det\begin{pmatrix} a_{11} & a_{12} \\ a_{21} & a_{22} \end{pmatrix} = a_{11}a_{22} - a_{21}a_{12}$ ហៅថាដេទែមីណង់នៃម៉ាទ្រីសការេ A ។

២ . $A = \begin{pmatrix} a_{11} & a_{12} & a_{13} \\ a_{21} & a_{22} & a_{23} \\ a_{31} & a_{32} & a_{33} \end{pmatrix}$ ផលគុណដំបូងទាំងអស់នៃម៉ាទ្រីស B

មាន $a_{11}a_{22}a_{33} \quad a_{12}a_{23}a_{31} \quad a_{13}a_{32}a_{21} \quad a_{31}a_{22}a_{13} \quad a_{32}a_{23}a_{11}$ និង $a_{21}a_{12}a_{33}$

ផលគុណដំបូងដែលមានសញ្ញាទាំងអស់នៃម៉ាទ្រីស B គឺ $a_{11}a_{22}a_{33} \quad a_{12}a_{23}a_{31} \quad a_{13}a_{32}a_{21} \quad -a_{31}a_{22}a_{13} \quad -a_{32}a_{23}a_{11}$ និង $-a_{21}a_{12}a_{33}$

ដូចនេះ $\det(B) = \det \begin{pmatrix} a_{11} & a_{12} & a_{13} \\ a_{21} & a_{22} & a_{23} \\ a_{31} & a_{32} & a_{33} \end{pmatrix}$

$$= a_{11}a_{22}a_{33} + a_{12}a_{23}a_{31} + a_{13}a_{32}a_{21} - a_{31}a_{22}a_{13} - a_{32}a_{23}a_{11} - a_{21}a_{12}a_{33}$$

ហៅថាដេទែមីណង់នៃម៉ាទ្រីសការេ B ។

Listing ៩.5: ដោះស្រាយតាម matlab

```
clear all
syms a_11 a_12 a_13 a_21 a_22 a_23 a_31 a_32 a_33
A = sym([a_11 a_12 ; a_21 a_22])
B = sym([a_11 a_12 a_13 ; a_21 a_22 a_23 ; a_31 a_32 a_33])
X = det(A)
Y = det(B)
```

ទ្រឹស្តីបទ ១.៦. បើ A ជាម៉ាទ្រីសការេ ហើយមានចម្រាស នោះ $\det(A^{-1}) = \dfrac{1}{\det(A)}$ ។

ដំណោះស្រាយ

បើ A ជាម៉ាទ្រីសការេហើយមានចម្រាសនោះ

គេបាន $\quad AA^{-1} = I$

$$\Rightarrow \det(AA^{-1}) = \det(I) = 1$$

$$\Rightarrow \det(A)\det(A^{-1}) = 1 \quad ,\text{ព្រោះ } \det(AB) = \deg(A).\det(B)$$

បើ $\det(A) \neq 0$ នោះ $\dfrac{\det(A).\det(A^{-1})}{\det(A)} = \dfrac{1}{\det(A)}$

$$\Rightarrow \det(A^{-1}) = \frac{1}{\det(A)}$$

៤.៣. ការគណនាដេទែមីណង់ដោយប្រើវិធី SARUSE

គេឲ្យ A ជាម៉ាទ្រីសការេលំដាប់ 3×3 ដែល $\begin{pmatrix} a_{11} & a_{12} & a_{13} \\ a_{21} & a_{22} & a_{23} \\ a_{31} & a_{32} & a_{33} \end{pmatrix}$

$$\det(A) = \left|\begin{array}{ccc:cc} a_{11} & a_{12} & a_{13} & a_{11} & a_{12} \\ a_{21} & a_{22} & a_{23} & a_{21} & a_{22} \\ a_{31} & a_{32} & a_{33} & a_{31} & a_{32} \end{array}\right|$$

$= a_{11}a_{22}a_{33} + a_{12}a_{23}a_{31} + a_{13}a_{32}a_{21} - a_{31}a_{22}a_{13} - a_{32}a_{23}a_{11} - a_{21}a_{12}a_{33}$

ចំណាំ ១.៧. វិធី SARUSE អនុវត្តន៍បានចំពោះម៉ាទ្រីសលំដាប់ 3×3 តែប៉ុណ្ណោះ ។

ឧទាហរណ៍ ១.១៩. គណនាដេទែមីណង់នៃម៉ាទ្រីស $A = \begin{pmatrix} 1 & 0 & 2 \\ 3 & 1 & 2 \\ 0 & 2 & 1 \end{pmatrix}$ ។

ដំណោះស្រាយ

គេមាន $A = \begin{pmatrix} 1 & 0 & 2 \\ 3 & 1 & 2 \\ 0 & 2 & 1 \end{pmatrix}$

គេបាន $\det(A) = A = \begin{pmatrix} 1 & 0 & 2 & \vdots & 1 & 0 \\ 3 & 1 & 2 & \vdots & 3 & 1 \\ 0 & 2 & 1 & \vdots & 0 & 2 \end{pmatrix}$

$$= (1)(1)(1) + (0)(2)(0) + (2)(3)(2) - (0)(1)(2) - (2)(2)(1) - (1)(3)(0)$$

$$= 9$$

ដូចនេះ $\boxed{\det(A) = 9}$

Listing 9.6: ដោះស្រាយដោយប្រើ matlab

```
format rat
a = [1 0 2 ; 3 1 2 ; 0 2 1];
answer = det(a)
```

៤.៤. ការគណនាដេទែមីណង់ចំពោះម៉ាទ្រីសត្រីកោណលើ ម៉ាទ្រីសត្រីកោណក្រោម និងម៉ាទ្រីសអង្កត់ទ្រូងពិសេស

និយមន័យ ១.១៤. បើ A ជាម៉ាទ្រីសការេលំដាប់ $n \times n$ (ម៉ាទ្រីសត្រីកោណលើ ម៉ាទ្រីសត្រីកោណក្រោម ឬម៉ាទ្រីសអង្កត់ទ្រូង) នោះ $\det(A)$ ស្មើនឹងផលគុណនៃធាតុនៅលើអង្កត់ទ្រូងសំខាន់គឺ $\det(A) = a_{11}a_{22}a_{33}\cdots a_{nn}$ ។

ឧទាហរណ៍ ១.២០. គេឲ្យបីម៉ាទ្រីការេ $A = \begin{pmatrix} a_{11} & a_{12} & a_{13} & a_{14} \\ 0 & a_{22} & a_{23} & a_{24} \\ 0 & 0 & a_{33} & a_{34} \\ 0 & 0 & 0 & a_{44} \end{pmatrix}$, $B = \begin{pmatrix} a_{11} & 0 & 0 & 0 & 0 \\ a_{21} & a_{22} & 0 & 0 & 0 \\ a_{31} & a_{32} & a_{33} & 0 & 0 \\ a_{41} & a_{42} & a_{43} & a_{44} & \end{pmatrix}$

និង $C = \begin{pmatrix} a_{11} & 0 & 0 & 0 \\ 0 & a_{22} & 0 & 0 \\ 0 & 0 & a_{33} & 0 \\ 0 & 0 & 0 & a_{44} \end{pmatrix}$

ដំណោះស្រាយ

- A ជាម៉ាទ្រីសត្រីកោណលើមានលំដាប់ 4×4 ដែល $A = \begin{pmatrix} a_{11} & a_{12} & a_{13} & a_{14} \\ 0 & a_{22} & a_{23} & a_{24} \\ 0 & 0 & a_{33} & 0 \\ 0 & 0 & 0 & a_{44} \end{pmatrix}$

  គេបាន $\det(A) = \det\begin{pmatrix} a_{11} & a_{12} & a_{13} & a_{14} \\ 0 & a_{22} & a_{23} & a_{24} \\ 0 & 0 & a_{33} & a_{34} \\ 0 & 0 & 0 & a_{44} \end{pmatrix} = a_{11}a_{22}a_{33}a_{44}$

- B ជាម៉ាទ្រីសត្រីកោណក្រោមលំដាប់ 5×5 ដែល $B = \begin{pmatrix} a_{11} & 0 & 0 & 0 & 0 \\ a_{11} & a_{22} & 0 & 0 & 0 \\ a_{11} & a_{22} & a_{33} & 0 & 0 \\ a_{11} & a_{22} & a_{33} & a_{44} & 0 \\ a_{11} & a_{22} & a_{33} & a_{44} & a_{55} \end{pmatrix}$

គេបាន $\det(B) = \det\begin{pmatrix} a_{11} & 0 & 0 & 0 & 0 \\ a_{11} & a_{22} & 0 & 0 & 0 \\ a_{11} & a_{22} & a_{33} & 0 & 0 \\ a_{11} & a_{22} & a_{33} & a_{44} & 0 \\ a_{11} & a_{22} & a_{33} & a_{44} & a_{55} \end{pmatrix} = a_{11}a_{22}a_{33}a_{44}a_{55}$

- C ជាម៉ាទ្រីសអង្កត់ទ្រូងពិសេសលំដាប់ 4×4 ដែល $C = \begin{pmatrix} a_{11} & 0 & 0 & 0 \\ 0 & a_{22} & 0 & 0 \\ 0 & 0 & a_{33} & 0 \\ 0 & 0 & 0 & a_4 \end{pmatrix}$

គេបាន $\det(C) = \det\begin{pmatrix} a_{11} & 0 & 0 & 0 \\ 0 & a_{22} & 0 & 0 \\ 0 & 0 & a_{33} & 0 \\ 0 & 0 & 0 & a_4 \end{pmatrix} = a_{11}a_{22}a_{33}a_{44}$

៤.៥. ការគណនាដេទែមីណង់ដោយប្រើបន្ទាត់ជួរដេក

ទ្រឹស្តីបទ ១.៧. បើ A ជាម៉ាទ្រីសការេមួយដែលមានជួរដេកមួយស្មើសូន្យនោះ $\det(A) = 0$ ។

សម្រាយបញ្ជាក់

គ្រប់ផលគុណដំបូងដែលមានសញ្ញាទាំងអស់ចេញពីម៉ាទ្រីស A មានកត្តាមួយចេញពីគ្រប់ជួរដេកទាំងអស់នៃ A នោះគ្រប់ផលគុណដំបូងដែលមានសញ្ញាទាំងអស់មានកត្តាមួយពីជួរ ដេកស្មើសូន្យ ដូច្នេះវាមានតម្លៃស្មើសូន្យ ។ ម៉្យាងទៀតដោយ $\det(A)$ ជាផលបូកនៃគ្រប់ផលគុណដំបូងដែលមាន សញ្ញាទាំងអស់ នោះយើងបាន $\det(A) = 0$ ។

ឧទាហរណ៍ ១.២១. គេឲ្យម៉ាទ្រីស $A = \begin{pmatrix} 3-x & 2 & 2 \\ 2 & 4-x & 1 \\ -2 & -4 & -1-x \end{pmatrix}$ ។ រកតម្លៃ x ដែល $\det(A) = 0$ ។

ដំណោះស្រាយ

គេបាន $\det(A)=\begin{vmatrix} 3-x & 2 & 2 \\ 2 & 4-x & 1 \\ -2 & -4 & -1-x \end{vmatrix}$

$$=(3-x)[-(4-x)(1+x)+4]-2[-2(1+x)+2]+2[-8+2(4-x)]$$

$$=(3-x)\left[x^2-3x\right]-2[-2x]+2[-2x]$$

$$=x\left[-(x-3)^2\right]$$

ដោយ $\det(A)=0$ នោះ $x\left[-(x-3)^2\right]=0$ នាំឲ្យ $x=0, x=3$

ទ្រឹស្តីបទ ១.៨. A ជាម៉ាទ្រីសការេលំដាប់ $n\times n$ និង k ជាចំនួនពិតមួយនោះ $|kA|=k^n|A|$ ។

សម្រាយបញ្ជាក់

$A=(a_{ij})_{1\le i\le n,1\le j\le n}\Rightarrow (kA)=(ka_{ij})_{1\le i\le n,1\le j\le n}$`

នោះគេបាន $\begin{pmatrix} ka_{11} & ka_{12} & \cdots & ka_{1n} \\ ka_{21} & ka_{22} & \cdots & ka_{2n} \\ \vdots & \vdots & \ddots & \vdots \\ ka_{n1} & ka_{n2} & \cdots & ka_{nn} \end{pmatrix} = k\begin{pmatrix} a_{11} & a_{12} & \cdots & a_{1n} \\ ka_{21} & ka_{22} & \cdots & ka_{2n} \\ \vdots & \vdots & \ddots & \vdots \\ ka_{n1} & a_{n2} & \cdots & ka_{nn} \end{pmatrix}$

$$= k^2\begin{pmatrix} a_{11} & a_{12} & \cdots & a_{1n} \\ a_{21} & a_{22} & \cdots & a_{2n} \\ \vdots & \vdots & \ddots & \vdots \\ ka_{n1} & a_{n2} & \cdots & ka_{nn} \end{pmatrix}$$

$$=\cdots\cdots\cdots\cdots\cdots\cdots\cdots\cdots$$

$$= k^n\begin{pmatrix} a_{11} & a_{12} & \cdots & a_{1n} \\ a_{21} & a_{22} & \cdots & a_{2n} \\ \vdots & \vdots & \ddots & \vdots \\ a_{n1} & a_{n2} & \cdots & a_{nn} \end{pmatrix}$$

ដូចនេះ $\boxed{|kA|=k^n|A|}$

ទ្រឹស្តីបទ ១.៩. A ជាម៉ាទ្រីសការេលំដាប់ $n \times n$ ។

១. បើ B ជាម៉ាទ្រីសដែលបានមកដោយគុណជួរដេកមួយនៃ A និង ចំនួនថេរ k មួយនោះ $\det(B) = k\det(A)$ ឬ $\det(A) = \dfrac{1}{k}\det(B), k \neq 0$ ។

២. បើ B ជាម៉ាទ្រីសដែលបានមកដោយផ្លាស់ប្តូរទីតាំងទៅវិញទៅមកនៃជួរដេកពីរនៃ A នោះ $\det(B) = -\det(A)$ ឬ $\det(A) = -\det(B)$ ។

៣. បើ B ជាម៉ាទ្រីសដែលបានមកដោយយកចំនួនថេរ k ណាមួយទៅគុណនឹងជួរដេកណាមួយនៃម៉ាទ្រីស A ហើយទៅបូកនឹងជួរដេកមួយផ្សេងទៀតនៃម៉ាទ្រីស A នោះ $\det(A) = \det(B)$ ។

៤.៦. មីន័រ (Minor)

និយមន័យ ១.១៥. បើ A ជាម៉ាទ្រីសការេលំដាប់ $n \times n$ នោះមីន័រ (Minor) នៃជួរដេកទី i និងជួរឈរទី j កំណត់ដោយ M_{ij} គឺជាដេទែមីណង់នៃម៉ាទ្រីសរងនៃម៉ាទ្រីសការេ A ដែលបានមកដោយ លុបជួរដេកទី i និងជួរឈរទី j ចេញពីម៉ាទ្រីសការេ A ។

តាមនិយមន័យ A ជាម៉ាទ្រិសការេលំដាប់ $n \times n$ គេបាន

$$A = (a)_{i,j} = \begin{pmatrix} a_{11} & a_{12} & \cdots & a_{1(j-1)} & a_{1j} & a_{1(j+1)} & \cdots & a_{1(n-1)} & a_{1n} \\ a_{21} & a_{22} & \cdots & a_{2(j-1)} & a_{2j} & a_{2(j+1)} & \cdots & a_{2(n-1)} & a_{2n} \\ \vdots & \vdots & \ddots & \vdots & \vdots & \vdots & \ddots & \vdots & \vdots \\ a_{(i-1)1} & a_{(i-1)2} & \cdots & a_{(i-1)(j-1)} & a_{(i-1)j} & a_{(i-1)(j+1)} & \cdots & a_{(i-1)(n-1)} & a_{(i-1)n} \\ a_{i1} & a_{i2} & \cdots & a_{i(j-1)} & a_{ij} & a_{i(j+1)} & \cdots & a_{i(n-1)} & a_{in} \\ a_{(i+1)1} & a_{(i+1)2} & \cdots & a_{(i+1)(j-1)} & a_{(i+1)j} & a_{(i+1)(j+1)} & \cdots & a_{(i+1)(n-1)} & a_{(i+1)n} \\ \vdots & \vdots & \ddots & \vdots & \vdots & \vdots & \ddots & \vdots & \vdots \\ a_{(n-1)1} & a_{(n-1)2} & \cdots & a_{(n-1)(j-1)} & a_{(n-1)j} & a_{(n-1)(j+1)} & \cdots & a_{(n-1)(n-1)} & a_{(n-1)n} \\ a_{n1} & a_{n2} & \cdots & a_{n(j-1)} & a_{n-j} & a_{n(j+1)} & \cdots & a_{n(n-1)} & a_{nn} \end{pmatrix}$$

- $M_{11} = \begin{vmatrix} a_{11} & a_{12} & \cdots & a_{1(j-1)} & a_{1j} & a_{1(j+1)} & \cdots & a_{1(n-1)} & a_{1n} \\ a_{21} & a_{22} & \cdots & a_{2(j-1)} & a_{2j} & a_{2(j+1)} & \cdots & a_{2(n-1)} & a_{2n} \\ \vdots & \vdots & \ddots & \vdots & \vdots & \vdots & \ddots & \vdots & \vdots \\ a_{(i-1)1} & a_{(i-1)2} & \cdots & a_{(i-1)(j-1)} & a_{(i-1)j} & a_{(i-1)(j+1)} & \cdots & a_{(i-1)(n-1)} & a_{(i-1)n} \\ a_{i1} & a_{i2} & \cdots & a_{i(j-1)} & a_{ij} & a_{i(j+1)} & \cdots & a_{i(n-1)} & a_{in} \\ a_{(i+1)1} & a_{(i+1)2} & \cdots & a_{(i+1)(j-1)} & a_{(i+1)j} & a_{(i+1)(j+1)} & \cdots & a_{(i+1)(n-1)} & a_{(i+1)n} \\ \vdots & \vdots & \ddots & \vdots & \vdots & \vdots & \ddots & \vdots & \vdots \\ a_{(n-1)1} & a_{(n-1)2} & \cdots & a_{(n-1)(j-1)} & a_{(n-1)j} & a_{(n-1)(j+1)} & \cdots & a_{(n-1)(n-1)} & a_{(n-1)n} \\ a_{n1} & a_{n2} & \cdots & a_{n(j-1)} & a_{nj} & a_{n(j+1)} & \cdots & a_{n(n-1)} & a_{nn} \end{vmatrix}$

$$= \begin{vmatrix} a_{22} & \cdots & a_{2(j-1)} & a_{2j} & a_{2(j+1)} & \cdots & a_{2(n-1)} & a_{2n} \\ \vdots & \ddots & \vdots & \vdots & \vdots & \ddots & \vdots & \vdots \\ a_{(i-1)2} & \cdots & a_{(i-1)(j-1)} & a_{(i-1)j} & a_{(i-1)(j+1)} & \cdots & a_{(i-1)(n-1)} & a_{(i-1)n} \\ a_{i2} & \cdots & a_{i(j-1)} & a_{ij} & a_{i(j+1)} & \cdots & a_{i(n-1)} & a_{in} \\ a_{(i+1)2} & \cdots & a_{(i+1)(j-1)} & a_{(i+1)j} & a_{(i+1)(j+1)} & \cdots & a_{(i+1)(n-1)} & a_{(i+1)n} \\ \vdots & \ddots & \vdots & \vdots & \vdots & \ddots & \vdots & \vdots \\ a_{(n-1)2} & \cdots & a_{(n-1)(j-1)} & a_{(n-1)j} & a_{(n-1)(j+1)} & \cdots & a_{(n-1)(n-1)} & a_{(n-1)n} \\ a_{n2} & \cdots & a_{n(j-1)} & a_{nj} & a_{n(j+1)} & \cdots & a_{n(n-1)} & a_{nn} \end{vmatrix}$$

- $M_{1j} = \begin{vmatrix} a_{11} & a_{12} & \cdots & a_{1(j-1)} & a_{1j} & a_{1(j+1)} & \cdots & a_{1(n-1)} & a_{1n} \\ a_{21} & a_{22} & \cdots & a_{2(j-1)} & a_{2j} & a_{2(j+1)} & \cdots & a_{2(n-1)} & a_{2n} \\ \vdots & \vdots & \ddots & \vdots & \vdots & \vdots & \ddots & \vdots & \vdots \\ a_{(i-1)1} & a_{(i-1)2} & \cdots & a_{(i-1)(j-1)} & a_{(i-1)j} & a_{(i-1)(j+1)} & \cdots & a_{(i-1)(n-1)} & a_{(i-1)n} \\ a_{i1} & a_{i2} & \cdots & a_{i(j-1)} & a_{ij} & a_{i(j+1)} & \cdots & a_{i(n-1)} & a_{in} \\ a_{(i+1)1} & a_{(i+1)2} & \cdots & a_{(i+1)(j-1)} & a_{(i+1)j} & a_{(i+1)(j+1)} & \cdots & a_{(i+1)(n-1)} & a_{(i+1)n} \\ \vdots & \vdots & \ddots & \vdots & \vdots & \vdots & \ddots & \vdots & \vdots \\ a_{(n-1)1} & a_{(n-1)2} & \cdots & a_{(n-1)(j-1)} & a_{(n-1)j} & a_{(n-1)(j+1)} & \cdots & a_{(n-1)(n-1)} & a_{(n-1)n} \\ a_{n1} & a_{n2} & \cdots & a_{n(j-1)} & a_{nj} & a_{n(j+1)} & \cdots & a_{n(n-1)} & a_{nn} \end{vmatrix}$

$$= \begin{vmatrix} a_{21} & a_{22} & \cdots & a_{2(j-1)} & a_{2(j+1)} & \cdots & a_{2(n-1)} & a_{2n} \\ \vdots & \vdots & \ddots & \vdots & \vdots & \ddots & \vdots & \vdots \\ a_{(i-1)1} & a_{(i-1)2} & \cdots & a_{(i-1)(j-1)} & a_{(i-1)(j+1)} & \cdots & a_{(i-1)(n-1)} & a_{(i-1)n} \\ a_{i1} & a_{i2} & \cdots & a_{i(j-1)} & a_{i(j+1)} & \cdots & a_{i(n-1)} & a_{in} \\ a_{(i+1)1} & a_{(i+1)2} & \cdots & a_{(i+1)(j-1)} & a_{(i+1)(j+1)} & \cdots & a_{(i+1)(n-1)} & a_{(i+1)n} \\ \vdots & \vdots & \ddots & \vdots & \vdots & \ddots & \vdots & \vdots \\ a_{(n-1)1} & a_{(n-1)2} & \cdots & a_{(n-1)(j-1)} & a_{(n-1)(j+1)} & \cdots & a_{(n-1)(n-1)} & a_{(n-1)n} \\ a_{n1} & a_{n2} & \cdots & a_{n(j-1)} & a_{n(j+1)} & \cdots & a_{n(n-1)} & a_{nn} \end{vmatrix}$$

- $$M_{i1} = \begin{vmatrix} a_{11} & a_{12} & \cdots & a_{1(j-1)} & a_{1j} & a_{1(j+1)} & \cdots & a_{1(n-1)} & a_{1n} \\ a_{21} & a_{22} & \cdots & a_{2(j-1)} & a_{2j} & a_{2(j+1)} & \cdots & a_{2(n-1)} & a_{2n} \\ \vdots & \vdots & \ddots & \vdots & \vdots & \vdots & \ddots & \vdots & \vdots \\ a_{(i-1)1} & a_{(i-1)2} & \cdots & a_{(i-1)(j-1)} & a_{(i-1)j} & a_{(i-1)(j+1)} & \cdots & a_{(i-1)(n-1)} & a_{(i-1)n} \\ a_{i1} & a_{i2} & \cdots & a_{i(j-1)} & a_{ij} & a_{i(j+1)} & \cdots & a_{i(n-1)} & a_{in} \\ a_{(i+1)1} & a_{(i+1)2} & \cdots & a_{(i+1)(j-1)} & a_{(i+1)j} & a_{(i+1)(j+1)} & \cdots & a_{(i+1)(n-1)} & a_{(i+1)n} \\ \vdots & \vdots & \ddots & \vdots & \vdots & \vdots & \ddots & \vdots & \vdots \\ a_{(n-1)1} & a_{(n-1)2} & \cdots & a_{(n-1)(j-1)} & a_{(n-1)j} & a_{(n-1)(j+1)} & \cdots & a_{(n-1)(n-1)} & a_{(n-1)n} \\ a_{n1} & a_{n2} & \cdots & a_{n(j-1)} & a_{nj} & a_{n(j+1)} & \cdots & a_{n(n-1)} & a_{nn} \end{vmatrix}$$

$$= \begin{vmatrix} a_{12} & \cdots & a_{1(j-1)} & a_{1j} & a_{1(j+1)} & \cdots & a_{1(n-1)} & a_{1n} \\ a_{22} & \cdots & a_{2(j-1)} & a_{2j} & a_{2(j+1)} & \cdots & a_{2(n-1)} & a_{2n} \\ \vdots & \ddots & \vdots & \vdots & \vdots & \ddots & \vdots & \vdots \\ a_{(i-1)2} & \cdots & a_{(i-1)(j-1)} & a_{(i-1)j} & a_{(i-1)(j+1)} & \cdots & a_{(i-1)(n-1)} & a_{(i-1)n} \\ a_{(i+1)2} & \cdots & a_{(i+1)(j-1)} & a_{(i+1)j} & a_{(i+1)(j+1)} & \cdots & a_{(i+1)(n-1)} & a_{(i+1)n} \\ \vdots & \ddots & \vdots & \vdots & \vdots & \ddots & \vdots & \vdots \\ a_{(n-1)2} & \cdots & a_{(n-1)(j-1)} & a_{(n-1)j} & a_{(n-1)(j+1)} & \cdots & a_{(n-1)(n-1)} & a_{(n-1)n} \\ a_{n2} & \cdots & a_{n(j-1)} & a_{nj} & a_{n(j+1)} & \cdots & a_{n(n-1)} & a_{nn} \end{vmatrix}$$

- $$M_{ij} = \begin{vmatrix} a_{11} & a_{12} & \cdots & a_{1(j-1)} & a_{1j} & a_{1(j+1)} & \cdots & a_{1(n-1)} & a_{1n} \\ a_{21} & a_{22} & \cdots & a_{2(j-1)} & a_{2j} & a_{2(j+1)} & \cdots & a_{2(n-1)} & a_{2n} \\ \vdots & \vdots & \ddots & \vdots & \vdots & \vdots & \ddots & \vdots & \vdots \\ a_{(i-1)1} & a_{(i-1)2} & \cdots & a_{(i-1)(j-1)} & a_{(i-1)j} & a_{(i-1)(j+1)} & \cdots & a_{(i-1)(n-1)} & a_{(i-1)n} \\ a_{i1} & a_{i2} & \cdots & a_{i(j-1)} & a_{ij} & a_{i(j+1)} & \cdots & a_{i(n-1)} & a_{in} \\ a_{(i+1)1} & a_{(i+1)2} & \cdots & a_{(i+1)(j-1)} & a_{(i+1)j} & a_{(i+1)(j+1)} & \cdots & a_{(i+1)(n-1)} & a_{(i+1)n} \\ \vdots & \vdots & \ddots & \vdots & \vdots & \vdots & \ddots & \vdots & \vdots \\ a_{(n-1)1} & a_{(n-1)2} & \cdots & a_{(n-1)(j-1)} & a_{(n-1)j} & a_{(n-1)(j+1)} & \cdots & a_{(n-1)(n-1)} & a_{(n-1)n} \\ a_{n1} & a_{n2} & \cdots & a_{n(j-1)} & a_{nj} & a_{n(j+1)} & \cdots & a_{n(n-1)} & a_{nn} \end{vmatrix}$$

$$= \begin{vmatrix} a_{11} & a_{12} & \cdots & a_{1(j-1)} & a_{1(j+1)} & \cdots & a_{1(n-1)} & a_{1n} \\ a_{21} & a_{22} & \cdots & a_{2(j-1)} & a_{2(j+1)} & \cdots & a_{2(n-1)} & a_{2n} \\ \vdots & \vdots & \ddots & \vdots & \vdots & \ddots & \vdots & \vdots \\ a_{(i-1)1} & a_{(i-1)2} & \cdots & a_{(i-1)(j-1)} & a_{(i-1)(j+1)} & \cdots & a_{(i-1)(n-1)} & a_{(i-1)n} \\ a_{(i+1)1} & a_{(i+1)2} & \cdots & a_{(i+1)(j-1)} & a_{(i+1)(j+1)} & \cdots & a_{(i+1)(n-1)} & a_{(i+1)n} \\ \vdots & \vdots & \ddots & \vdots & \vdots & \ddots & \vdots & \vdots \\ a_{(n-1)1} & a_{(n-1)2} & \cdots & a_{(n-1)(j-1)} & a_{(n-1)(j+1)} & \cdots & a_{(n-1)(n-1)} & a_{(n-1)n} \\ a_{n1} & a_{n2} & \cdots & a_{n(j-1)} & a_{n(j+1)} & \cdots & a_{n(n-1)} & a_{nn} \end{vmatrix}$$

ឧទាហរណ៍ ១.២២. កំណត់មីន័រ (Minor) គ្រប់ជួរដេក និងជួរឈរនៃម៉ាទ្រីស $\begin{pmatrix} 1 & 2 & 3 \\ 0 & 2 & 0 \\ 2 & 1 & -2 \end{pmatrix}$ ។

ដំណោះស្រាយ

គេបាន $M_{11} = \begin{vmatrix} 2 & 0 \\ 1 & -2 \end{vmatrix} = -2(2) - 0(1) = -4$

$$M_{12} = \begin{vmatrix} 0 & 0 \\ 2 & -2 \end{vmatrix} = 0(-2) - 2(0) = 0$$

$$M_{13} = \begin{vmatrix} 0 & 2 \\ 2 & 1 \end{vmatrix} = 0(1) - 2(2) = -4$$

$$M_{21} = \begin{vmatrix} 2 & 3 \\ 1 & -2 \end{vmatrix} = 2(-2) - 1(3) = -7$$

$$M_{22} = \begin{vmatrix} 1 & 3 \\ 2 & -2 \end{vmatrix} = 1(-2) - 2(3) = -8$$

$$M_{23} = \begin{vmatrix} 1 & 2 \\ 2 & 1 \end{vmatrix} = 1(1) - 2(2) = -3$$

$$M_{31} = \begin{vmatrix} 2 & 3 \\ 2 & 0 \end{vmatrix} = 2(0) - 2(3) = -6$$

$$M_{32} = \begin{vmatrix} 1 & 3 \\ 0 & 0 \end{vmatrix} = 1(0) - 0(3) = 0$$

$$M_{33} = \begin{vmatrix} 1 & 2 \\ 0 & 2 \end{vmatrix} = 1(2) - 0(2) = 2$$

៤.៧. **កូហ្វេកទ័រ** (Cofactor)

និយមន័យ ១.១៦. កូហ្វេកទ័រ (Cofactor) នៃម៉ាទ្រីសការេ A តាងដោយ $Cof(A)$ ។ ជាម៉ាទ្រីសការេ ដែលធាតុរបស់វាជាមីន័រ (Minor) ទៅតាមលំដាប់ជួរដេកទី i និងជួរឈរទី j នៃម៉ាទ្រីសការេ A ដែរ ហើយរួមបញ្ចូលទាំងសញ្ញាទៅលើមីន័រ (Minor) នោះផង ។ គេកំណត់តាងធាតុនៃកូហ្វេកទ័រ $(Cofactor)$ ដោយ $c_{ij} = (-1)^{i+j} M_{ij}$ ។

តាមនិយមន័យគេបាន៖ $Cof(A) = (c_{ij})_{i\leq i\leq n, 1\leq j\leq n} = \left((-1)^{i+j}M_{ij}\right)_{1\leq j\leq n, 1\leq j\leq n}$ ដែល M_{ij} ជាមីន័រ $(Minor)$ នៃជួរដេកទី i និងជួរឈរទី j នៃម៉ាទ្រីសការេ A ។

ចំណាំ ១.៨. កូហ្វេកទ័រ (Cofactor) និង មីន័រ (Minor) នៃម៉ាទ្រីសការេ A នៃជួរដេកទី i និងជួរឈរទី j ខុសគ្នាតែសញ្ញាប៉ុណ្ណោះ ។ មានន័យថា $c_{ij} = (-1)^{i+j}M_{ij}$ ។ ខាងក្រោមនេះជាសញ្ញាម៉ាទ្រីស $Cofactor$ $\begin{pmatrix} + & - & + & - & + & \cdots \\ - & + & - & + & - & \cdots \\ + & - & + & - & + & \cdots \\ \vdots & \vdots & \vdots & \vdots & \vdots & \ddots \end{pmatrix}$

ឧទាហរណ៍ ១.២៣. កំណត់ Cofactor នៃ A ដែល $A = \begin{pmatrix} 2 & -1 & 3 \\ -3 & 0 & 1 \\ -2 & 1 & 2 \end{pmatrix}$ ។

ដំណោះស្រាយ

គេបាន $M_{11} = \begin{vmatrix} 0 & 1 \\ 1 & 2 \end{vmatrix} = 0(2) - 1(1) = -1 \Rightarrow C_{11} = (-1)^{1+1}M_{11} = -1$

$$M_{12} = \begin{vmatrix} -3 & 1 \\ -2 & 2 \end{vmatrix} = -3(2) + 2(1) = -4 \Rightarrow C_{12} = (-1)^{1+2}M_{12} = 4$$

$$M_{13} = \begin{vmatrix} -3 & 0 \\ -2 & 1 \end{vmatrix} = -3(1) + 2(0) = -3 \Rightarrow C_{13} = (-1)^{1+3}M_{13} = -3$$

$$M_{21} = \begin{vmatrix} -1 & 3 \\ 1 & 2 \end{vmatrix} = -1(2) - 1(3) = -5 \Rightarrow C_{21} = (-1)^{2+1}M_{21} = 5$$

នាំឲ្យ $\vec{v}_1 = \begin{pmatrix} x \\ y \\ z \end{pmatrix} = \begin{pmatrix} -\frac{3t}{2} \\ -\frac{t}{2}t \\ t \end{pmatrix} = \begin{pmatrix} -\frac{3}{2} \\ -\frac{1}{2} \\ 1 \end{pmatrix} t, t \in \mathbb{R}$

ដូចនេះ $\boxed{\text{វ៉ិចទ័រផ្ទាល់ (Eigenvector) នៃម៉ាទ្រីស } A \text{ គឺ } \vec{v}_1 = \begin{pmatrix} -\frac{4}{3} \\ -\frac{1}{3} \\ 1 \end{pmatrix} t, \vec{v}_2 = \begin{pmatrix} -\frac{3}{2} \\ -\frac{1}{2} \\ 1 \end{pmatrix} t \quad , t \in \mathbb{R}}$

៨. ការគណនាស្វ័យគុណរបស់ម៉ាទ្រីស (Computing Powers of a Matrix)

និយមន័យ ១.១២. ម៉ាទ្រីសអង្កត់ទ្រូងកម្ម: កាលណាម៉ាទ្រីស A ហៅថាម៉ាទ្រីសអង្កត់ទ្រូង (Diagonalizable Matrix) បើមានម៉ាទ្រីសមានចម្រាស P ដែល $P^{-1}AP$ ជាម៉ាទ្រីសអង្កត់ទ្រូងកម្ម ។ គេហៅ P ជាម៉ាទ្រីសដែលធ្វើអង្កត់ទ្រូងកម្មទៅលើ A ។

សម្រាយបញ្ជាក់

ឧបមាថា A ជាម៉ាទ្រីសអង្កត់ទ្រូងកម្ម នោះវាជាម៉ាទ្រីសមានចម្រាស $\begin{pmatrix} P_{11} & P_{12} & \cdots & P_{1n} \\ P_{21} & P_{22} & \cdots & P_{2n} \\ \vdots & \vdots & \ddots & \vdots \\ P_{n1} & P_{n2} & \cdots & P_{nm} \end{pmatrix}$ ដែល $P^{-1}AP = D$

និង $D = \begin{pmatrix} \lambda_1 & 0 & \cdots & 0 \\ 0 & \lambda_2 & \cdots & 0 \\ \vdots & \vdots & \ddots & \vdots \\ 0 & 0 & \cdots & \lambda_n \end{pmatrix}$ មានន័យថា $\lambda_1, \lambda_2, \cdots, \lambda_n$ និង $P_1, P_2, \cdots, P_n$ គឺជាតម្លៃផ្ទាល់ និងវ៉ិចទ័រផ្ទាល់ រៀងគ្នានៃម៉ាទ្រីស A ។

បើ A ជាម៉ាទ្រីសមានលំដាប់ $n \times n$ ហើយ P ជាម៉ាទ្រីសមានចម្រាសនោះ

$$P^{-1}AP = D \Leftrightarrow P(P^{-1}AP)P^{-1} = PDP^{-1} \Leftrightarrow A = PDP^{-1}$$

គេបាន $A^k = \underbrace{\left(PDP^{-1}\right)\left(PDP^{-1}\right)\ldots\left(PDP^{-1}\right) = PD^kP^{-1}}_{k}, k \in \mathbb{N}$

សមីការបានបង្ហាញនូវស្វ័យគុណទី k នៃ A ជាអនុគមន៍នៃស្វ័យគុណទី k របស់ម៉ាទ្រីសអង្កត់ទ្រូង។ តែគេអាចគណនាដោយងាយដូចជា៖

$$\text{បើ} \quad D = \begin{pmatrix} \lambda_1 & 0 & \ldots & 0 \\ 0 & \lambda_2 & \ldots & 0 \\ \vdots & \vdots & \ddots & \vdots \\ 0 & 0 & \ldots & \lambda_n \end{pmatrix} \quad \text{នោះ} \quad D^k = \begin{pmatrix} \lambda_1^k & 0 & \ldots & 0 \\ 0 & \lambda_2^k & \ldots & 0 \\ \vdots & \vdots & \ddots & \vdots \\ 0 & 0 & \ldots & \lambda_n^k \end{pmatrix}$$

ឧទាហរណ៍ ១.៤០. គណនា A^n ចំពោះចំនួនគត់ធម្មជាតិមិនសូន្យនៃម៉សទ្រីស $= \begin{bmatrix} 1 & 2 \\ 2 & 1 \end{bmatrix}$ ។

ដំណោះស្រាយ

- រក eigenvalues នៃម៉ាទ្រីស A

  គេបាន $\det(A - \lambda I) = \begin{vmatrix} 1-\lambda & 2 \\ 2 & 1-\lambda \end{vmatrix}$

  $$= (1-\lambda)^2 - 4 = \lambda^2 - 2\lambda - 3$$

  $$= (\lambda+1)(\lambda-3) = 0$$

  $$\Rightarrow \lambda_1 = -1, \lambda_2 = 3$$

- រក eigenvector

- ចំពោះ $\lambda=-1$ នាំឲ្យ $(A+I)\vec{v}_1=0$

  គេបាន $\begin{pmatrix}2&2\\2&2\end{pmatrix}\begin{pmatrix}v\\y\end{pmatrix}=\begin{pmatrix}0\\0\end{pmatrix}\Leftrightarrow 2x+2y=0\Leftrightarrow x=y$

  យក $y=t\Rightarrow x=t, t\in\mathbb{R}$ នាំឲ្យ $\vec{v}_1=\begin{pmatrix}x\\y\end{pmatrix}=\begin{pmatrix}t\\t\end{pmatrix}=\begin{pmatrix}1\\1\end{pmatrix}t$

- ចំពោះ $\lambda=3$ នាំឲ្យ $(A-3I)\vec{v}_1=0$

  គេបាន $\begin{pmatrix}-2&2\\2&-2\end{pmatrix}\begin{pmatrix}v\\y\end{pmatrix}=\begin{pmatrix}0\\0\end{pmatrix}\Leftrightarrow -2x+2y=0 \quad\Leftrightarrow x=-y$

  យក $y=t\Rightarrow x=-t, t\in\mathbb{R}$ នាំឲ្យ $\vec{v}_1=\begin{pmatrix}x\\y\end{pmatrix}=\begin{pmatrix}-t\\t\end{pmatrix}=\begin{pmatrix}-1\\1\end{pmatrix}t$

- រក P ជាម៉ាទ្រីសដែលធ្វើអង្កត់ទ្រូងកម្មទៅលើ A

  នាំឲ្យ $P=[\vec{v_1},\vec{v_2}]=\begin{bmatrix}-1&1\\1&1\end{bmatrix}$ នោះ $P^{-1}=\dfrac{1}{\det(P)}\text{adj}(A)=\dfrac{1}{2}\begin{bmatrix}1&-1\\1&1\end{bmatrix}$

  គេបាន $P^{-1}AP=\begin{bmatrix}-1&0\\0&3\end{bmatrix}$ ឬ $A=P\begin{bmatrix}-1&0\\0&3\end{bmatrix}P^{-1}$

- រក A^n ចំពោះ $n\in\mathbb{N}$

  គេបាន $A^n=\left(P\begin{bmatrix}-1&0\\0&3\end{bmatrix}P^{-1}\right)^n=P\begin{bmatrix}-1&0\\0&3\end{bmatrix}^nP^{-1}=P\begin{bmatrix}(-1)^n&0\\0&3^n\end{bmatrix}P^{-1}$

  $$=\begin{bmatrix}1&1\\-1&1\end{bmatrix}\begin{bmatrix}(-1)^n&0\\0&3^n\end{bmatrix}\frac{1}{2}\begin{bmatrix}1&-1\\1&1\end{bmatrix}=\frac{1}{2}\begin{bmatrix}(-1)^n+3^n&(-1)^{n+1}+3^n\\(-1)^{n+1}+3^n&(-1)^n+3^n\end{bmatrix}$$

  ដូចនេះ $\boxed{A^n=\dfrac{1}{2}\begin{bmatrix}(-1)^n+3^n&(-1)^{n+1}+3^n\\(-1)^{n+1}+3^n&(-1)^n+3^n\end{bmatrix}}$

ឧទាហរណ៍ ១.៤១. គណនា A^n ចំពោះម៉ាទ្រីស $A=\begin{pmatrix}4&2&2\\2&4&2\\2&2&4\end{pmatrix}$ ។

ដំណោះស្រាយ

គេបាន $\det(A-\lambda I)=\begin{vmatrix}4-\lambda&2&2\\2&4-\lambda&2\\2&2&4-\lambda\end{vmatrix}$

$$=\left[(4-\lambda)^3+8+8\right]-[4(4-\lambda)+4(4-\lambda)+4(4-\lambda)]=(\lambda-8)(\lambda-2)^2$$

តែ $\det(A-\lambda I)=0\Leftrightarrow(\lambda-8)(\lambda-2)^2=0\Rightarrow\lambda_1=2,\lambda_2=8$ វាជា Eigenvalues នៃ A

- ចំពោះ $\lambda_1 = 2$ នោះ $\begin{pmatrix} 2 & 2 & 2 \\ 2 & 2 & 2 \\ 2 & 2 & 2 \end{pmatrix}\begin{pmatrix} x \\ y \\ z \end{pmatrix} = \begin{pmatrix} 0 \\ 0 \\ 0 \end{pmatrix} \Leftrightarrow \begin{cases} 2x+2y+2z=0 & (1) \\ 2x+2y+2z=0 & (2) \\ 2x+2y+2z=0 & (3) \end{cases}$

  បើយក $y = t, z = r$ ដែល $t, r \in \mathbb{R}$ តាម$(1):\ x = -t - r$

  គេបាន $\vec{v} = \begin{pmatrix} -t-r \\ t \\ r \end{pmatrix} = \begin{pmatrix} -t \\ t \\ 0 \end{pmatrix} + \begin{pmatrix} -r \\ 0 \\ r \end{pmatrix} = \begin{pmatrix} -1 \\ 1 \\ 0 \end{pmatrix} t + \begin{pmatrix} -1 \\ 0 \\ 1 \end{pmatrix} r$

  នោះ $\vec{v}_1 = \begin{pmatrix} -1 \\ 1 \\ 0 \end{pmatrix}, \vec{v}_2 = \begin{pmatrix} -1 \\ 0 \\ 1 \end{pmatrix}$

- ចំពោះ $\lambda_2 = 8$ នោះ $\begin{pmatrix} -4 & 2 & 2 \\ 2 & -4 & 2 \\ 2 & 2 & -4 \end{pmatrix}\begin{pmatrix} x \\ y \\ z \end{pmatrix} = \begin{pmatrix} 0 \\ 0 \\ 0 \end{pmatrix} \Leftrightarrow \begin{cases} -4x+2y+2z=0 & (1) \\ 2x-4y+2z=0 & (2) \\ 2x+2y-4z=0 & (3) \end{cases}$

  យក $(1)-(2):\ -6x+6y=0 \Rightarrow x = y$ បើយក $y = t \Rightarrow x = t, t \in \mathbb{R}$

  តាម $(1):\ z = \frac{1}{2}x + \frac{1}{2}y = \frac{1}{2}t + \frac{1}{2}t = t$

  គេបានវ៉ិចទ័រផ្ទាល់ដែលត្រូវនឹងវាគឺ $\vec{v}_3 = \begin{pmatrix} t \\ t \\ t \end{pmatrix} = \begin{pmatrix} 1 \\ 1 \\ 1 \end{pmatrix} t, t \in \mathbb{R}$

  នោះ $D = \begin{pmatrix} 2 & 0 & 0 \\ 0 & 2 & 0 \\ 0 & 0 & 8 \end{pmatrix} \Rightarrow D^n = \begin{pmatrix} 2^n & 0 & 0 \\ 0 & 2^n & 0 \\ 0 & 0 & 8^n \end{pmatrix}$

  គេបាន $P = [\vec{v}_1, \vec{v}_2, \vec{v}_3] = \begin{pmatrix} -1 & -1 & 1 \\ 1 & 0 & 1 \\ 0 & 1 & 1 \end{pmatrix}$

  នោះ $\left(\begin{array}{ccc|ccc} -1 & -1 & 1 & 1 & 0 & 0 \\ 1 & 0 & 1 & 0 & 1 & 0 \\ 0 & 1 & 1 & 0 & 0 & 1 \end{array}\right) \sim \left(\begin{array}{ccc|ccc} -1 & -1 & 1 & 1 & 0 & 0 \\ 0 & -1 & 2 & 1 & 1 & 0 \\ 0 & 1 & 1 & 0 & 0 & 1 \end{array}\right) L_2 \to L_1 + L_2$

$$\sim \left(\begin{array}{ccc|ccc} -1 & -1 & 1 & 1 & 0 & 0 \\ 0 & 1 & -2 & -1 & -1 & 0 \\ 0 & 0 & 3 & 1 & 1 & 1 \end{array}\right) \begin{array}{l} L_2 \to -L_2 \\ L_3 \to L_2 + L_3 \end{array}$$

$$\sim \left(\begin{array}{ccc|ccc} 1 & 1 & -1 & -1 & 0 & 0 \\ 0 & 1 & -2 & -1 & -1 & 0 \\ 0 & 0 & 1 & \frac{1}{3} & \frac{1}{3} & \frac{1}{3} \end{array}\right) \begin{array}{l} L_1 \to -L_1 \\ L_3 \to \dfrac{L_3}{3} \end{array}$$

$$\sim \left(\begin{array}{ccc|ccc} 1 & 1 & 0 & -\frac{2}{3} & \frac{1}{3} & \frac{1}{3} \\ 0 & 1 & 0 & -\frac{1}{3} & -\frac{1}{3} & \frac{2}{3} \\ 0 & 0 & 1 & \frac{1}{3} & \frac{1}{3} & \frac{1}{3} \end{array}\right) \begin{array}{l} L_1 \to L_1 + L_3 \\ L_2 \to L_2 + 2L_3 \end{array}$$

$$\sim \left(\begin{array}{ccc|ccc} 1 & 0 & 0 & -\frac{1}{3} & \frac{2}{3} & -\frac{1}{3} \\ 0 & 1 & 0 & -\frac{1}{3} & -\frac{1}{3} & \frac{2}{3} \\ 0 & 0 & 1 & \frac{1}{3} & \frac{1}{3} & \frac{1}{3} \end{array}\right) L_1 \to L_1 - L_2$$

គេបាន $P^{-1} = \begin{pmatrix} -\frac{1}{3} & \frac{2}{3} & -\frac{1}{3} \\ -\frac{1}{3} & -\frac{1}{3} & \frac{2}{3} \\ \frac{1}{3} & \frac{1}{3} & \frac{1}{3} \end{pmatrix} = \frac{1}{3}\begin{pmatrix} -1 & 2 & -1 \\ -1 & -1 & 2 \\ 1 & 1 & 1 \end{pmatrix}$

គេបាន $A = PDP^{-1} \Rightarrow A^n = PD^nP^{-1}$

$$= \begin{pmatrix} -1 & -1 & 1 \\ 1 & 0 & 1 \\ 0 & 1 & 1 \end{pmatrix} \begin{pmatrix} 2^n & 0 & 0 \\ 0 & 2^n & 0 \\ 0 & 0 & 8^n \end{pmatrix} \cdot \frac{1}{3} \begin{pmatrix} -1 & 2 & -1 \\ -1 & -1 & 2 \\ 1 & 1 & 1 \end{pmatrix}$$

$$= \frac{1}{3} \begin{pmatrix} -2^n & -2^n & 8^n \\ 2^n & 0 & 8^n \\ 0 & 2^n & 8^n \end{pmatrix} \begin{pmatrix} -1 & 2 & -1 \\ -1 & -1 & 2 \\ 1 & 1 & 1 \end{pmatrix}$$

$$= \frac{1}{3} \begin{pmatrix} -2^n & -2^n & 8^n \\ 2^n & 0 & 8^n \\ 0 & 2^n & 8^n \end{pmatrix} \begin{pmatrix} -1 & 2 & -1 \\ -1 & -1 & 2 \\ 1 & 1 & 1 \end{pmatrix}$$

$$= \frac{1}{3} \begin{pmatrix} 2^n + 2^n + 8^n & -2 \cdot 2^n + 2^n + 8^n & 2^n - 2 \cdot 2^n + 8^n \\ -2^n + 8^n & 2.2^n + 8^n & -2^n + 8^n \\ -2^n + 8^n & -2^n + 8^n & 2.2^n + 8^n \end{pmatrix}$$

$$= \frac{1}{3} \begin{pmatrix} 2^{n+1} + 8^n & -2^n + 8^n & -2^n + 8^n \\ -2^n + 8^n & 2^{n+1} + 8^n & -2^n + 8^n \\ -2^n + 8^n & -2^n + 8^n & 2^{n+1} + 8^n \end{pmatrix}$$

ដូចនេះ $\boxed{A^n = \frac{1}{3}\begin{pmatrix} 2^{n+1}+8^n & -2^n+8^n & -2^n+8^n \\ -2^n+8^n & 2^{n+1}+8^n & -2^n+8^n \\ -2^n+8^n & -2^n+8^n & 2^{n+1}+8^n \end{pmatrix}, n \in \mathbb{N}}$

៩. រ៉ង់នៃម៉ាទ្រីស (Rank of Matrix)

ឧទាហរណ៍ ១.៤២. រ៉ង់នៃម៉ាទ្រីសមួយគឺជាចំនួនជួរដេកមិនសូន្យក្នុងទម្រង់បន្ថយជួរដេកនៃម៉ាទ្រីស ឬចំនួននៃជួរឈរនាំមុខ ។ គេកំណត់សរសេរដោយ $Rank(A) = r$ ។

ចំណាំ ១.១៣. • ម៉ាទ្រីសក្នុងទម្រង់ជួរដេកអាចនិយាយថាស្ថិតក្នុងទម្រង់ The Echelon Form ។ បើវាជា The Echelen Form ប្រសិនបើ៖

១. ជួរដេកមិនសូន្យ r របស់វាស្ថិតនៅក្នុងផ្នែកខាងលើនៃម៉ាទ្រីស ។

២. ក្នុងជួរឈរនាំមុខទី i ធាតុទាំងអស់ខាងក្រោមជួរដេកទី i ស្មើសូន្យ ។

• វិធីសម្រួលម៉ាទ្រីសមួយជាទម្រង់កាត់បន្ថយជួរដេក ហៅថាវិធីបំបាត់ Gauss Jordan Elimination ហើយវិធីសម្រួលម៉ាទ្រីសមួយជាទម្រង់ The Echelon Form ហៅថា Gauss Jordan Elimination ។

ឧទាហរណ៍ ១.៤៣. រករ៉ង់នៃម៉ាទ្រីស៖

១. $A = \begin{pmatrix} 1 & 5 & 1 \\ 2 & 1 & 1 \\ 3 & 6 & 2 \end{pmatrix}$

២. $B = \begin{pmatrix} 1 & 2 & 1 \\ -2 & -3 & 1 \\ 3 & 5 & 0 \end{pmatrix}$

ដំណោះស្រាយ

១. គេបាន $A = \begin{pmatrix} 1 & 5 & 1 \\ 2 & 1 & 1 \\ 3 & 6 & 2 \end{pmatrix} r_2 \to r_2 - 2R_1 \begin{pmatrix} 1 & 5 & 1 \\ 0 & -9 & -1 \\ 3 & 6 & 2 \end{pmatrix} r_3 \to r_3 - 3r_1 \begin{pmatrix} 1 & 5 & 1 \\ 0 & -9 & -1 \\ 0 & -9 & -1 \end{pmatrix}$

$r_3 \to r_2/-9 \begin{pmatrix} 1 & 5 & 1 \\ 0 & -9 & -1 \\ 0 & -9 & -1 \end{pmatrix} r_3 \to r_3 + 9r_2 \begin{pmatrix} 1 & 5 & 1 \\ 0 & 1 & 1/9 \\ 0 & 0 & 0 \end{pmatrix}$

ដូចនេះ $\boxed{\text{រ៉ង់នៃ } A \text{ គឺ } Rank(A) = 2}$

២. គេបាន $\begin{pmatrix} 1 & 2 & 1 \\ -2 & -3 & 1 \\ 3 & 5 & 0 \end{pmatrix}$

$R_2 \to 2r_1 + r_2 \begin{pmatrix} 1 & 2 & 1 \\ 0 & 1 & 3 \\ 3 & 5 & 0 \end{pmatrix} R_3 \to -3r_1 + r_3 \begin{pmatrix} 1 & 2 & 1 \\ 0 & 1 & 3 \\ 0 & -1 & -3 \end{pmatrix}$

$R_3 \to r_2 + r_3 \begin{pmatrix} 1 & 2 & 1 \\ 1 & 2 & 1 \\ 0 & 0 & 0 \end{pmatrix} R_1 \to -2r_1 \begin{pmatrix} 1 & 0 & -5 \\ 0 & 1 & 3 \\ 0 & 0 & 0 \end{pmatrix}$

ដូចនេះ $\boxed{\text{រ៉ង់នៃ } B \text{ គឺ } Rank(B) = 2}$

Listing ១.21: ដោះស្រាយតាម matlab

```
clear all
A=[1 5 1 ; 2 1 1 ; 3 6 2];
B=[1 2 1 ; -2 -3 1 ; 3 5 0];
eq1 = rank(B)
eq2 = rank(B)
```

សម្គាល់ ១. ចំពោះឧទាហរណ៍ទី២ គេអាចប្រើទម្រង់កាត់បន្ថយជួរដេកសម្រាប់ដោះស្រាយប្រពន្ធ័សមីការ $AX = B$

ដែល $A = \begin{pmatrix} a_{11} & a_{12} & \dots & a_{1n} \\ a_{21} & a_{22} & \cdots & a_{2n} \\ \vdots & \vdots & \ddots & \vdots \\ a_{m1} & a_{m2} & \cdots & a_{mn} \end{pmatrix}$ ដោយសរសេរជា The augmented matrix

$$A|B = \left(\begin{array}{cccc|c} a_{11} & a_{12} & \dots & a_{1n} & b_1 \\ a_{21} & a_{22} & \cdots & a_{2n} & b_2 \\ \vdots & \vdots & \ddots & \vdots & \vdots \\ a_{m1} & a_{m2} & \cdots & a_{mn} & b_m \end{array}\right)$$

ទ្រឹស្តីបទ ១.១៣. ឧបមាថា $m \times n$ ប្រពន្ធ័សមីការលីនេអ៊ែរ $AX = B$ ។ តាង $A|B$ ជា The augented matrix នៃប្រពន្ធ័ ។

១. បើ $Rank(A) < Rank(A|B)$ ប្រពន្ធ័សមីការគ្មានចម្លើយ

២. បើ $Rank(A) = Rank(A|B) = n$ ប្រពន្ធ័សមីការមានសំណុំចម្លើយតែមួយគាត់

៣. បើ $Rank(A) = Rank(A|B) < n$ ប្រពន្ធ័សមីការមានសំណុំចម្លើយច្រើនរាប់មិនអស់ ។

ឧទាហរណ៍ ១.៤៤. ដោះស្រាយប្រព័ន្ធសមីការខាងក្រោម៖

១. $\begin{cases} x+y-z+t &= 1 \\ 2x+3y+z &= 4 \\ 3x+5y+3z-t &= 5 \end{cases}$ ២. $\begin{cases} x+y+z &= 4 \\ x+2y+z &= 5 \\ x-y &= -1 \end{cases}$

ដំណោះស្រាយ

១. $\begin{cases} x+y-z+t &= 1 \\ 2x+3y+z &= 4 \\ 3x+5y+3z-t &= 5 \end{cases}$ សរសេរទៅជា The augment matrix

គេបាន $\left(\begin{array}{cccc|c} 1 & 1 & -1 & 1 & 1 \\ 2 & 3 & 1 & 0 & 4 \\ 3 & 5 & 3 & -1 & 5 \end{array}\right) \sim \left(\begin{array}{cccc|c} 1 & 1 & -1 & 1 & 1 \\ 0 & 1 & 3 & -2 & 2 \\ 0 & 2 & 6 & -4 & 2 \end{array}\right) \begin{array}{l} R_2-2R_1 \to R_2 \\ R_3-3R_1 \to R_3 \end{array}$

$\sim \left(\begin{array}{cccc|c} 1 & 0 & -4 & 3 & -1 \\ 0 & 1 & 3 & -2 & 2 \\ 0 & 0 & 0 & 0 & -2 \end{array}\right) \begin{array}{l} R_1-R_2 \to R_1 \\ R_3-2R_2 \to R_3 \end{array}$

ដោយ $Rank(a)=2 < Rank(a|B)=3$ នាំឲ្យប្រព័ន្ធសមីការគ្មានចម្លើយ

ដូចនេះ $\boxed{\text{ប្រព័ន្ធសមីការគ្មានចម្លើយ}}$

Listing ១.22: ដោះស្រាយតាម matlab

```
clear all
syms x y z t
eqn1 = x+y-z +t == 1;
eqn2 = 2*x+3*y+z  == 4;
eqn3 = 3*x+5*y+3*z-t == 5;
[A,B] = equationsToMatrix([eqn1, eqn2,eqn3], [x,y,z,t])
X = linsolve(A,B)
```

២. $\begin{cases} x+y+z &= 4 \\ x+2y+z &= 5 \\ x-y &= -1 \end{cases}$ សរសេរទៅជា The augmented matrix

គេបាន $\left(\begin{array}{ccc|c} 1 & 1 & 1 & 4 \\ 1 & 2 & 1 & 5 \\ 1 & -1 & 0 & -1 \end{array}\right) \sim \left(\begin{array}{ccc|c} 1 & 1 & 1 & 4 \\ 0 & 1 & 0 & 1 \\ 0 & 2 & 1 & 5 \end{array}\right) \begin{array}{l} R_2 - R_1 \to R_2 \\ R_1 - R_3 \to R_3 \end{array}$

$$\sim \begin{pmatrix} 1 & 0 & 1 \\ 0 & 1 & 0 \\ 0 & 0 & 1 \end{pmatrix} \begin{array}{l} R_1 - R_2 \to R_1 \\ R_3 - 2R_2 \to R_3 \end{array}$$

$$\sim \left(\begin{array}{ccc|c} 1 & 0 & 0 & 0 \\ 0 & 1 & 0 & 1 \\ 0 & 0 & 1 & 3 \end{array}\right) R_1 - R_3 \to R_1$$

យើងសង្កេតឃើញថា $Rank(c) = Rank(c|B) = n = 3$ នោះប្រពន្ធ័សមីការមានសំណុំចម្លើយតែមួយគត់ ។

ដូចនេះ $\boxed{\text{ប្រពន្ធ័សមីការមានសំណុំចម្លើយតែមួយគត់គឺ } x = 0, y = 1, z = 3}$ ។

Listing ១.23: ដោះស្រាយតាម matlab

```
clear all
syms x y z
eqn1 = x+y+z == 4;
eqn2 = x+2*y+z  == 5;
eqn3 = x-y == -1;
[A,B] = equationsToMatrix([eqn1, eqn2,eqn3], [x,y,z])
X = linsolve(A,B)
```

ជំពូក២ ការអនុវត្តន៍ម៉ាទ្រីស

១. ទ្រឹស្តីបរមាកម្ម

១.១. ការបង្កើតទម្រង់នៃបញ្ហាកម្មវិធីលីនេអ៊ែរ (Formation of LP Problem)

១.១.១. គម្រូកម្មវិធីលីនេអ៊ែរ (The LP Models)

ក. **អថេរសម្រេចចិត្ត** (Decision Variables) ជាបរិមាណផលិតផលដែលត្រូវសម្រេចចិត្ត ផលិតក្នុងបញ្ហាផលិតផលចម្រុះ ឬជាបរិមាណវត្ថុធាតុដើមដែលត្រូវសម្រេចចិត្តទិញក្នុងបញ្ហាល្បាយដើម្បីទទួលបានចម្លើយប្រសើរបំផុត (Optimal Solution) គឺចំណេញអតិបរមា ឬចំណាយថ្លៃដើមអប្បបរមា។ ដើម្បីធ្វើបែបនេះបាន គេត្រូវតាងអថេរដោយអក្សរមានន័យថា តាងឲ្យបរិមាណទាំងឡាយដែលយើងត្រូវរកតម្លៃរបស់វាក្នុងការដោះស្រាយចំណោទ។ ជាធម្មតាគេតាង $x_1, x_2, x_3, \cdots, x_n$ ជា n អថេរសម្រេចចិត្តនៃចំណោទកម្មវិធីលីនេអ៊ែរ។

ខ. **អនុគមន៍គោលដៅ** (Objective Function) សំដៅទៅដល់កន្សោម ដែលប្រាប់ពីទំនាក់ទំនងរវាងទិន្នន័យ និងប្រាក់ចំណេញ។ ចំណោទកម្មវិធីលីនេអ៊ែរនីមួយៗមានអនុគមន៍គោលដៅតែមួយគត់ដែលគេអាចសរសេរជារាងលីនេអ៊ែរ $z = c_1x_1 + c_2x_2 + c_3x_3 + \cdots + c_nx_n$ ដែល $c_1, c_2, c_3, \cdots, c_n$ ជាចំនួនពិតថេរ ហើយ z ត្រូវរកតម្លៃអតិបរមា ឬអប្បបរមារបស់វា។

គ. កម្រិតព្រំដែល (Constraints) ជារាល់លក្ខខណ្ឌដែលបានកំណត់ ឬកម្រិតក្នុងចំណោទ។ លក្ខណ្ឌទាំងនេះអាចសរសេរជាទម្រង់សមីការ ឬវិសមីការលីនេអ៊ែរ។

១.១.២. ការបង្កើតរូបមន្តសម្រាប់បញ្ហា LP (The Formulation of the LP Problems)

ក្នុងការដោះស្រាយចំណោទនៃការបង្កើតកម្មវិធីលីនេអ៊ែរមួយ ជាដំបូងយើងត្រូវបង្កើតរូបមន្តជាទម្រង់នៃគណិតវិទ្យា។ ដើម្បីធ្វើបានដូចនេះយើងត្រូវកំណត់ឲ្យបានច្បាស់នូវៈ

១. អថេរសម្រេចចិត្ត (Decision Variables)

២. អនុគមន៍គោលដៅ (Objective Function)

៣. កម្រិតព្រំដែន (Constriants)

១.២. ការបង្កើតកម្មវិធីគម្រូគណិតវិទ្យាសម្រាប់ចំណោទនៃគម្រោងការងារ ចំណោទចម្រុះ និងចំណោទនៃដំណើរការផលិតកម្ម

ឧទាហរណ៍ ២.១. ប្រៃសនីយ៍មួយកន្លែងត្រូវការចំនួនបុគ្គលិកធ្វើការពេញម៉ោងផ្សេងៗ នៅថ្ងៃខុសៗគ្នា។ ច្បាប់សហជីពចែងថា បុគ្គលិកធ្វើការពេញម៉ោងត្រូវ ធ្វើការថ្ងៃជាប់ៗគ្នាហើយបន្ទាប់មកត្រូវបានឈប់សម្រាកពីរថ្ងៃ។ ឧទាហរណ៍ បុគ្គលិកដែលធ្វើការពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ ត្រូវឈប់សម្រាកនៅថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ។ ចំនួនបុគ្គលិកធ្វើការពេញម៉ោងត្រូវធ្វើការតាមថ្ងៃដែលបានកំណត់ដូចក្នុងតារាងខាងក្រោម។ ចូរបង្កើតរូបមន្ត LP មួយ ដើម្បីឲ្យប្រៃសនីយ៍នេះប្រើប្រាស់បុគ្គលិកធ្វើការពេញម៉ោងដែលគេត្រូវជួលនេះតិចបំផុត។

តារាងកម្មករដែលត្រូវធ្វើការសម្រាប់ប្រៃសនីយ៍

		ចំនួនបុគ្គលិកធ្វើការពេញម៉ោង
ថ្ងៃទី១	ចន្ទ	17
ថ្ងៃទី២	អង្គារ	13
ថ្ងៃទី៣	ពុធ	15
ថ្ងៃទី៤	ព្រហស្បត្តិ៍	19
ថ្ងៃទី៥	សុក្រ	14
ថ្ងៃទី៦	សៅរ៍	16
ថ្ងៃទី៧	អាទិត្យ	11

ដំណោះស្រាយ

តាង x_i ជាចំនួនបុគ្គលិកដែលចាប់ផ្តើមធ្វើការនៅក្នុងថ្ងៃ i ។

គេបាន x_1 ជាចំនួនបុគ្គលិកដែលចាប់ផ្តើមធ្វើការនៅថ្ងៃចន្ទ (បុគ្គលិកទាំងនេះធ្វើការពីថ្ងៃចន្ទដល់ថ្ងៃសុក្រ)

x_2 ជាចំនួនបុគ្គលិកដែលចាប់ផ្តើមធ្វើការនៅថ្ងៃអង្គារ (បុគ្គលិកទាំងនេះធ្វើការពីថ្ងៃអង្គារដល់ថ្ងៃសៅរ៍)

x_3 ជាចំនួនបុគ្គលិកដែលចាប់ផ្តើមធ្វើការនៅថ្ងៃពុធ (បុគ្គលិកទាំងនេះធ្វើការពីថ្ងៃពុធដល់ថ្ងៃអាទិត្យ)

x_4 ជាចំនួនបុគ្គលិកដែលចាប់ផ្តើមធ្វើការនៅថ្ងៃព្រហស្បត្តិ៍ (បុគ្គលិកទាំងនេះធ្វើការពីថ្ងៃព្រហស្បត្តិ៍ដល់ថ្ងៃចន្ទ)

x_5 ជាចំនួនបុគ្គលិកដែលចាប់ផ្តើមធ្វើការនៅថ្ងៃសុក្រ (បុគ្គលិកទាំងនេះធ្វើការពីថ្ងៃសុក្រដល់ថ្ងៃអង្គារ)

x_6 ជាចំនួនបុគ្គលិកដែលចាប់ផ្តើមធ្វើការនៅថ្ងៃសៅរ៍ (បុគ្គលិកទាំងនេះធ្វើការពីថ្ងៃសៅរ៍ដល់ថ្ងៃពុធ)

x_7 ជាចំនួនបុគ្គលិកដែលចាប់ផ្តើមធ្វើការនៅថ្ងៃអាទិត្យ (បុគ្គលិកទាំងនេះធ្វើការពីថ្ងៃអាទិត្យដល់ថ្ងៃព្រហស្បតិ៍)

ចំនួនបុគ្គលិកធ្វើការពេញម៉ោង $=$ ចំនួនបុគ្គលិកចាប់ផ្តើមធ្វើការថ្ងៃចន្ទ $+$ ចំនួនបុគ្គលិកចាប់ផ្តើមធ្វើការថ្ងៃអង្គារ $+\cdots+$ ចំនួនបុគ្គលិកចាប់ផ្តើមធ្វើការថ្ងៃអាទិត្យ

គេបាន អនុគមន៍គោលដៅគឺ $MinZ = x_1 + x_2 + x_3 + x_4 + x_5 + x_6 + x_7$

ប្រៃសនីយ៍ត្រូវប្រាកដថាយ៉ាងហោចណាស់មានមនុស្ស 17 នាក់ធ្វើការនៅថ្ងៃចន្ទ។ បុគ្គលិកទាំងអស់ត្រូវធ្វើការនៅថ្ងៃចន្ទ លើកលែងតែបុគ្គលិកដែលចាប់ផ្តើមធ្វើការថ្ងៃអង្គារនិងថ្ងសពុធ (ព្រោះពួកគេត្រូវឈប់សម្រាកនៅ ថ្ងៃអាទិត្យនិងថ្ងៃចន្ទ ថ្ងៃចន្ទ

និងថ្ងៃអង្គារ រៀងគ្នា)។ នេះមានន័យថាចំនួនបុគ្គលិកដែលធ្វើការនៅថ្ងៃចន្ទគឺ $x_1+x_4+x_5+x_6+x_7$ ។ ដូចគ្នាដែរចំពោះថ្ងៃផ្សេងទៀត។

រូបមន្ត LP នៃចំណោទនេះគឺៈ $MinZ = x_1+x_2+x_3+x_4+x_5+x_6+x_7$

ចន្ទ $x_1+x_4+x_5+x_6+x_7 \geq 17$

អង្គារ $x_1+x_2+x_5+x_6+x_7 \geq 13$

ពុធ $x_1+x_2+x_3+x_6+x_7 \geq 15$

ព្រហស្បត្តិ៍ $x_1+x_2+x_3+x_4+x_7 \geq 19$

សុក្រ $x_1+x_2+x_3+x_4+x_5 \geq 14$

សៅរ៍ $x_2+x_3+x_4+x_5+x_6 \geq 16$

អាទិត្យ $x_3+x_4+x_5+x_6+x_7 \geq 11$

$x_i \geq 0 \qquad (i = 1,2,3,4,5,6,7)$

១.៣. ដំណោះស្រាយចំណោទលីនេអ៊ែរ (LP) តាមក្រាបហ្វិច

១. **ជំហានទី១៖** ក្នុងការដោះស្រាយចំណោទនៃការបង្កើតកម្មវិធីលីនេអ៊ែរមួយ ជាដំបូងគេត្រូវបង្កើតរូបមន្តជាទម្រង់នៃគណិតវិទ្យា។ ដើម្បីធ្វើបានដូចនេះយើងត្រូវកំណត់ឲ្យបានច្បាស់នូវៈ

   ក. អថេរសម្រេចចិត្ត (Decision Variables)

   ខ. អនុគមន៍គោលដៅ (Objective Function)

   គ. កម្រិតព្រំដែន (Constriants)

២. **ជំហានទី២៖** ពេលនេះយើងត្រូវគូសកម្រិតព្រំដែននៃចំណោទក្នុងក្រាហ្វិចមួយ។ ដើម្បីឲ្យបានជាចម្លើយដែលយើងចង់បាន ចម្លើយនោះត្រូវតែផ្ទៀងផ្ទាត់ចំពោះកម្រិតព្រំដែនទាំងអស់។

៣. **ជំហានទី៣៖** យើងត្រូវដៅចំណុចកាច់ជ្រុងទាំងអស់ជុំវិញតំបន់ចម្លើយ។

៤. **ជំហានទី៤៖** យកចំណុចកាច់ជ្រុងនៃតំបន់ចម្លើយជំនួសក្នុងអនុគមន៍គោលដៅ។ បន្ទាប់មកសង្កេតមើលតម្លៃដែលប្រសើរបំផុត (អតិបរមា ឬអប្បបរមា)។

ឧទាហរណ៍ ២.២. មីងសីនួនចង់លាយម្សៅសណ្ដែក ស្ករសនិងទឹកដើម្បីធ្វើភេជ្ជៈពីរប្រភេទគឺទឹកសណ្ដែកសនិងទឹកសណ្ដែកខៀវ ។ ទឹកសណ្ដែកសធ្វើពីស្ករស 20% ម្សៅសណ្ដែក 20% និងទឹក 60% ហើយទឹកសណ្ដែកខៀវធ្វើពីស្ករស 40% មស្សៅសណ្ដែក 20% និងទឹក 40% ។ មីងស៊ីនួនចំណេញបាន 60 សេនក្នុង $1kg$ នៃទឹកសណ្ដែកស និងបានចំណេញ 80 សេនក្នុង $1kg$ នៃទឹកសណ្ដែកខៀវ។ ប្រសិនបើគាត់មានស្ករសរ $60kg$ និងម្សៅសណ្ដែក $40kg$ នោះគាត់អាចផលិតទឹកសណ្ដែកប្រភេទនីមួយៗបានប៉ុន្មានគីឡូក្រាម ដើម្បីឲ្យគាត់ទទួលបានប្រាក់ចំណេញខ្ពស់បំផុត ?

ដំណោះស្រាយ

រកចំនួនទឹកសណ្តែកស និងខៀវដែលត្រូវផលិតដើម្បីទទួលប្រាក់ចំណេញអតិបរមា

- តារាងសង្ខេប

	ស្ករស	ម្សៅសណ្តែក	ទឹក	ប្រាក់ចំណេញ
ទឹកសណ្តែកស	0.2	0.2	0.6	$0.6\$/1kg$
ទឹកសណ្តែកខៀវ	0.4	0.2	0.4	$0.8\$/1kg$
វត្ថុដែលមានសរុប	$60kg$	$40kg$		

- បង្កើតអនុគមន៍គោលដៅ

តាង x ជាទឹកសណ្តែកស និង y ជាទឹកសណ្តែកខៀវ

Max P: $z = 0.6x + 0.8y$ និង S.t $\begin{cases} 0.2x + 0.4y \leq 60 \\ 0.2x + 0.2y \leq 40 \\ x, y \geq 0 \end{cases}$

$0.2x + 0.4y \leq 60$ ការប្រើស្ករសដើម្បីផលិតទឹកសណ្តែកស និងខៀវយ៉ាងច្រើន $60kg$

$0.2x + 0.2y \leq 40$ ការប្រើម្សៅសណ្តែកដើម្បីផលិតទឹកសណ្តែកស និងខៀវយ៉ាងច្រើន $40kg$ ។

- សង់បន្ទាត់

តារាងតម្លៃលេខ

$0.2x + 0.4y = 60$

x	0	300
y	150	0

$0.2x + 0.2y = 40$

x	0	200
y	200	0



- តាមក្រាបចម្លើយដែលអាចទទួលយកបានគឺនៅត្រង់តំបន់ពត៌ខៀវ និងចំណុចកាច់ជ្រុង

- រកកូអរដោនេនៃចំណុច B ដែលជាប្រសព្វរវាងបន្ទាត់ទាំងពីរ

គេបាន $\begin{cases} 0.2x + 0.4y = 60 \\ 0.2x + 0.2y = 40 \end{cases} \sim L_2 = R_1 - R_2 : \begin{cases} 0.2x + \quad 0.4y = 60 \\ \qquad\quad 0.2y = 20 \end{cases} \Rightarrow \begin{cases} y = \dfrac{20}{0.2} = 100 \\ x = \dfrac{60 - 0.2(100)}{0.4} = 100 \end{cases}$

- តម្លៃនៃចំណុចកាច់ជ្រុង

  - $0(0,0) \Rightarrow z = 0$
  - $A(0,150) \Rightarrow z = 0.6(0) + 0.8(150) = 120$
  - $B(100,100) \Rightarrow z = 0.6(100) + 0.8(100) = 140$
  - $C(200,0) \Rightarrow z = 0.6(200) + 0.8(0) = 120$

ដូចនេះ $\boxed{\text{ចម្លើយដែលប្រសើរបំផុតគឺ } x = 0, y = 200 \text{ ដើម្បីទទួលបានចំណេញអតិបរមា } 160\$}$

ឧទាហរណ៍ ២.៣. ក្រុមហ៊ុន TOYOTA តម្លើងរថយន្តពីរប្រភេទគឺឡានតូច (Car) និងឡានដឹកទំនិញ (Van) នៅទីក្រុង Bang Kok ។ រថយន្តនីមួយៗត្រូវឆ្លងកាត់ហាងបាញ់ថ្នាំ និងហាងតម្លើង។ ប្រសិន បើហាងបាញ់ថ្នាំត្រូវបានគេរៀបចំរួចរាល់សម្រាប់ឡានតូច នោះគេអាចបាញ់ថ្នាំឡានតូចបានចំនួន 800 ក្នុងមួយថ្ងៃ។ ប្រសិនបើហាងបាញ់ថ្នាំត្រូវបានគេរៀបចំរួចរាល់សម្រាប់ឡានដឹង ទំនិញនោះគេអាចបាញ់ថ្នាំឡានដឹកទំនិញបានចំនួន 700 ក្នុងមួយថ្ងៃ។ ប្រសិនបើហាងតម្លើងត្រូវបានគេរៀបចំរួចរាល់សម្រាប់ឡានតូច នោះគេអាចតម្លើងឡានតូចបានចំនួន 1700 ក្នុងមួយថ្ងៃ។ ប្រើសិនបើហាងតម្លើងត្រូវបានគេរៀបចំរួចរាល់សម្រាប់ឡានដឹកទំនិញ នោះគេអាចតម្លើងឡានដឹកទំនិញបានចំនួន 1200 ក្នុងមួយថ្ងៃ។ ឡានតូចនីមួយៗផ្តល់ប្រាក់ចំណេញបាន 300\$ និងឡានដឹកទំនិញផ្តល់បាន 500\$ ចូរអ្នកបង្កើតរូបមន្តតាមបែបកម្មវិធីលីនេអ៊ែរដែលនឹងធ្វើឲ្យប្រាក់ចំណេញរបស់ក្រុមហ៊ុន TOYOTA ឡើងដល់កម្រិតអតិបរមា។ បន្ទាប់មកដោះស្រាយតាមក្រាបហ្វិច។

ដំណោះស្រាយ

រកចំនួន Car និង Van ដែលត្រូវផលិតដើម្បីឲ្យបានប្រាក់ចំណេញជាអតិបរមា

- តារាងសង្ខេប

	Car	Van
ផ្នែកបាញ់ថ្នាំ	$1/180$	$1/700$
ផ្នែកតម្លើង	$1/1700$	$1/1200$
ប្រាក់ចំណេញ	300	

$\frac{1}{800}$ មានន័យថាមួយថ្ងៃបាញ់ថ្នាំ Car បាន 800 គ្រឿង
$\frac{1}{700}$ មានន័យថាមួយថ្ងៃបាញ់ថ្នាំ Van បាន 700 គ្រឿង
$\frac{1}{1700}$ មានន័យថាមួយថ្ងៃតម្លើង Car បាន 1700 គ្រឿង
$\frac{1}{1200}$ មានន័យថាមួយថ្ងៃតម្លើង Van បាន 1200 គ្រឿង

- បង្កើតអនុគមន៍គោលដៅ

  តាង x ជាចំនួន Car និង y ជាចំនួន Van

  MaxP: $z = 300x + 500y$ និង S.t $\begin{cases} \dfrac{1}{800}x + \dfrac{1}{700}y & \leq 1 \\ \dfrac{1}{1700}x + \dfrac{1}{1200}y & \leq 1 \\ x, y \geq 0 \end{cases}$

- ដំណោះស្រាយតាមក្រាប

$\dfrac{1}{800}x + \dfrac{1}{700}y = 1$

x	0	800
y	700	0

$\dfrac{1}{1700}x + \dfrac{1}{1200}y = 1$

x	0	1700
y	1200	0



- តាមក្រាបចម្លើយដែលអាចទទួលបានគឺនៅត្រង់តំបន់ចំណុចកាច់ជ្រុងតម្លៃនៃចំណុចកាចជ្រុង

  - $A(0,0) = 0$
  - $B(800,0) \Rightarrow z = 300(800) + 500(0) = 240000$
  - $C(0,700) \Rightarrow z = 300(0) + 500(700) = 350000$

ដូចនេះ: ក្រុមហ៊ុន TOYOTA ត្រូវផលិត Car ចំនួន 0 និង Van ចំនួន 700 ដើម្បីឲ្យប្រាក់ចំណេញអតិបរមា 350 000\$

២. អនុវត្តម៉ាទ្រីសក្នុងវ៉ិចទ័រ

២.១. ចម្ងាយពីចំណុចទៅចំណុចនៅក្នុងលំហ



បើគេមានចំណុច $A(x_A, y_A, z_A)$ និង $B(x_B, y_B, z_B)$ នោះគេបាន៖

- វ៉ិចទ័រ $\overrightarrow{AB} = (x_B - x_A, y_B - y_A, z_B - z_A)$
  $= (x_B - x_A)\vec{i} + (y_B - y_A)\vec{j} + (z_B - z_A)\vec{k}$
- ប្រវែង $AB = |\overrightarrow{AB}| = \sqrt{(x_B - x_A)^2 + (y_B - y_A)^2 + (z_B - z_A)^2}$

ឧទាហរណ៍ ២.៤. គេមានចំណុច $A(1, 2, 3)$ និង $B(2, 1, 2)$ ។ គណនាប្រវែង AB ។

<u>**ដំណោះស្រាយ**</u>

តាមរូបមន្ត
$$AB = \sqrt{(x_B - x_A)^2 + (y_B - y_A)^2 + (z_B - Z_A)^2}$$
$$= \sqrt{(2-1)^2 + (1-2)^2 + (2-3)^2}$$
$$= \sqrt{1^2 + 1^2 + 1^2}$$
$\therefore \quad AB = \sqrt{3}$ ឯកត្តាប្រវែង

២.២. ផលគុណនៃពីរវ៉ិចទ័រ

បើ $\vec{u}$ និង $\vec{v}$ ជាពីរវ៉ិចទ័រមិនសូន្យនៅក្នុងលំហ និង តាង α ជាមុំរវាងពីរវ៉ិចទ័រ $\vec{u}$ និង $\vec{v}$ ។ ផលគុណនៃពីរវ៉ិចទ័រ $\vec{u}$ និង $\vec{v}$ គឺជាវ៉ិចទ័រមួយតាងដោយ $\vec{u} \times \vec{v}$ ឬ $\vec{u} \wedge \vec{v}$ ។

មានន័យថា $(\vec{u} \times \vec{v}) \perp \vec{u}$ និង $(\vec{u} \times \vec{v}) \perp \vec{v}$ ។



រូប២.១

តាង $\vec{u} \times \vec{v} = (x, y, z), \vec{u} = (u_1, u_2, u_3)$ និង $\vec{v} = (v_1, v_2, v_3)$

ដោយ $(\vec{u} \times \vec{v}) \perp \vec{u} \Leftrightarrow (\vec{u} \times \vec{v}).\vec{u} = u_1 x + u_2 y + u_3 z = 0 \quad (1)$

$(\vec{u} \times \vec{v}) \perp \vec{v} \Leftrightarrow (\vec{u} \times \vec{v}).\vec{v} = v_1 x + v_2 y + v_3 z = 0 \quad (2)$

តាម (1) និង (2) ចងជាប្រព័ន្ធសមីការ

គេបាន $\begin{cases} u_1 x + u_2 y + u_3 z = 0 \\ v_1 x + v_2 y + v_3 z = 0 \end{cases} \Rightarrow L_2 = v_1.L_1 - u_1.L_2 : \begin{cases} u_1 x + u_2 y + u_3 z = 0 \\ (u_2 v_1 - u_1 v_2) y + (u_3 v_1 - u_1 v_3) z = 0 \end{cases}$

$$\Rightarrow \frac{y}{x}=\frac{3v_1-u_1v_3}{u_1b_2-u_2v_1} \Rightarrow y=(u_3v_1-u_1v_3)t \text{ និង } z=(u_1v_2-u_2v_1)t \text{ ចំពោះ } t\neq 0$$

ជំនួសចូលសមីការ (1) គេបាន $u_1x=-u_3\left(u_1v_2-u_2v_1\right)t-u_2\left(u_3v_1-u_1v_3\right)t$

$$=\left(-u_1u_3v_2+u_2u_3v_1-u_2u_3v_1+u_1u_2v_3\right)t$$

$$u_1x=u_1\left(u_2v_3-u_3v_2\right)t$$

$$x=\left(u_2v_3-u_3v_2\right)t$$

យក $t=1$ គេបាន $\vec{u}\times\vec{v}=(x,y,z)=(u_2v_3-u_3b_2,u_3v_1-u_1v_3,u_1v_2-u_2v_1)$

$$=\left(u_2v_3-u_3b_2\right)\overrightarrow{i}-\left(u_1v_3-u_3v_1\right)\overrightarrow{j}+\left(u_1v_2-u_2v_1\right)\overrightarrow{k}$$

ដូចនេះ $\boxed{\vec{u}\times\vec{v}=\begin{vmatrix}u_2 & u_3\\ v_2 & v_3\end{vmatrix}\overrightarrow{i}-\begin{vmatrix}u_1 & u_3\\ v_1 & v_3\end{vmatrix}\overrightarrow{j}+\begin{vmatrix}u_1 & u_2\\ v_1 & v_2\end{vmatrix}\overrightarrow{k}}$

ចំណាំ ២.១. បើ $\vec{u}=(u_1,u_2,u_3),\vec{v}=(v_1,v_2,v_3)$ នោះគេបាន $\vec{u}\times\vec{v}=\begin{vmatrix}\overrightarrow{i} & \overrightarrow{j} & \overrightarrow{k}\\ u_1 & u_2 & u_3\\ v_1 & v_2 & v_3\end{vmatrix}$

ទ្រឹស្តីបទ ២.១. បើ $\vec{n}$ ជាវ៉ិចទ័រឯកត្តា $(|n|=1)$ ហើយអរតូកូណាល់ទៅនឹង $\vec{u}$ ផងនិង $\vec{v}$ ផងនោះគេបាន វ៉ិចទ័រ $\vec{u}\times\vec{v}=|\vec{u}|.|\vec{v}|.\sin\alpha.\vec{n}$ ឬ $|\vec{u}\times\vec{v}|=|\vec{u}|.|\vec{v}|.\sin\alpha$ ។

សម្រាយបញ្ជាក់

គេមាន $|\vec{u}|^2|\vec{v}|^2\sin^2\alpha=|\vec{u}|^2|\vec{v}|^2(1-\sin^2\alpha)$

$$=|\vec{u}|^2|\vec{v}|^2-|a|^2|b|^2\cos^2\alpha$$

$$=|\vec{u}|^2|\vec{v}|^2-(\vec{u}.\vec{v})^2$$

$$=(u_1^2+u_2^2+u_3^2)(v_1^2+v_2^2+v_3^2)-(u_1v_1+u_2v_2+u_3v_3)^2$$

$$=(u_2v_3-u_3v_2)^2+(u_3v_1-u_1v_3)^2+(u_1v_2-u_2v_1)^2$$

$$=|\vec{u}\times\vec{v}|^2$$

$$|\vec{u}\times\vec{v}|=|\vec{u}||\vec{v}|\sin\alpha \quad ,\sin\alpha>0$$

ទ្រឹស្តីបទ ២.២. ចំពោះ $\vec{u}$ និង $\vec{v}$ ជាពីរវ៉ិចទ័រក្នុងតម្រុយ $(0, \overrightarrow{i}, \overrightarrow{j}, \overrightarrow{k})$ នោះគេបាន៖

១. បើ $\vec{u} \times \vec{v} = \vec{0}$ នោះ $\vec{u}$ និង $\vec{v}$ កូលីនេអ៊ែនឹងគ្នា ។

២. $|\vec{u} \times \vec{v}|$ ជាផ្ទៃក្រឡានៃប្រលេឡូក្រាម ដែលលងលើ $\vec{u}$ និង $\vec{v}$ ។

៣. $\dfrac{1}{2}|\vec{u} \times \vec{v}|$ ជាផ្ទៃក្រឡានៃត្រីកោណ ដែលលងលើ $\vec{u}$ និង $\vec{v}$ ។

៤. A, B, C ជាបីចំណុចរតមិនត្រង់គ្នា លុះត្រាតែ $\overrightarrow{AB} \times \overrightarrow{AC} = \vec{0}$ ។

សម្រាយបញ្ជាក់

១. តាមទ្រឹស្តីបទ ២.១ : $\vec{u} \times \vec{v} = |\vec{u}|.|\vec{v}| \sin\alpha.\vec{n}$ ដោយ $\vec{u}$ និង $\vec{v}$ កូលីនេអ៊ែនឹងគ្នា នោះ $\alpha = 0 \Rightarrow \sin\alpha = 0$ នោះគេបាន $\vec{u} \times \vec{v} = 0$ ។

២. ក្នុង រូប២.១: គេបានក្រឡាផ្ទៃប្រលេឡូក្រាម
$$\begin{aligned} S &= |\vec{u}|.h \\ &= |\vec{u}|.|\vec{v}|.\sin\alpha \quad \text{តាមទ្រឹស្តីបទ ២.១} \\ \therefore \quad S &= |\vec{u} \times \vec{v}| \end{aligned}$$

៣. ផ្ទៃក្រឡានៃត្រីកោណ $S_{\triangle} = \dfrac{1}{2}S = \dfrac{1}{2}|\vec{u} \times \vec{v}|$

៤. គេមាន $\overrightarrow{AB} \times \overrightarrow{AC} = \vec{0}$ លុះត្រាតែ $\overrightarrow{AB}$ កូលីនេអ៊ែ $\overrightarrow{AC}$ លុះត្រាតែ ចំណុច A, B, C រត់មិនត្រង់គ្នា ។

ឧទាហរណ៍ ២.៥. គេឲ្យចំណុច $A(1,3,2), B(2,-1,1), C(-1,2,3)$ ។ គណនា ក្រលាផ្ទៃត្រីកោណ ABC ។

ដំណោះស្រាយ

គណនា $S_{\triangle ABC}$

គេមាន $A(1,3,2), B(2,-1,1), C(-1,2,3)$

នោះ $\overrightarrow{AB} = (2-1)\overrightarrow{i} + (-1-3)\overrightarrow{j} + (1-2)\overrightarrow{k} = \overrightarrow{i} - 4\overrightarrow{j} - \overrightarrow{k}$

$\overrightarrow{AC} = (-1-1)\overrightarrow{i} + (2-3)\overrightarrow{j} + (3-2)\overrightarrow{k} = -2\overrightarrow{i} - \overrightarrow{j} + \overrightarrow{k}$

គេបាន $\overrightarrow{AB} \times \overrightarrow{AC} = \begin{vmatrix} \overrightarrow{i} & \overrightarrow{j} & \overrightarrow{k} \\ 1 & -4 & -1 \\ -2 & -1 & 1 \end{vmatrix} = (-4-1)\overrightarrow{i} - (1-2)\overrightarrow{j} + (-1-8)\overrightarrow{k} = -5\overrightarrow{i} + \overrightarrow{j} - 9\overrightarrow{k}$

នាំឲ្យ $S_{\triangle ABC} = \dfrac{1}{2}|\overrightarrow{AB} \times \overrightarrow{AC}| = \dfrac{1}{2}\sqrt{5^2 + 1^2 + 9^2} = \dfrac{1}{2}\sqrt{107}$ ឯកត្តាក្រលាផ្ទៃ ។

២.៣. កន្សោមផលគុណនៃពីរវ៉ិចទ័រក្នុងគោលអរតូណរម៉ាល់មានទិសដៅវិជ្ជមាន

បើ $\vec{u} = u_1\vec{i}+u_2\vec{j}+u_3\vec{k} = (u_1, u_2, u_3)$ និង $\vec{v} = v_1\vec{i}+v_2\vec{j}+v_3\vec{k} = (v_1, v_2, v_3)$ ជាវ៉ិចទ័រក្នុងលំហ ។ ផលគុណនៃពីរវ៉ិចទ័រ $\vec{u}$ និង $\vec{v}$ គឺជាវ៉ិចទ័រកំណត់ដោយ៖ $\vec{u}\times\vec{v} = \begin{vmatrix} \vec{i} & \vec{j} & \vec{k} \\ u_1 & u_2 & u_3 \\ v_1 & v_2 & v_3 \end{vmatrix} = \begin{vmatrix} u_2 & u_3 \\ v_2 & v_3 \end{vmatrix}\vec{i} - \begin{vmatrix} u_1 & u_3 \\ v_1 & v_3 \end{vmatrix}\vec{j} + \begin{vmatrix} u_1 & u_2 \\ v_1 & v_2 \end{vmatrix}\vec{k}$

$$\vec{u}\times\vec{v} = (u_2v_3 - u_3v_2)\vec{i} - (u_1v_3 - u_3v_1)\vec{j} + (u_1v_2 - u_2v_1)\vec{k} \qquad (២.១)$$

ឧទាហរណ៍ ២.៦. គណនា $|\vec{u}\times\vec{v}|$ បើ $\vec{u} = 2\overrightarrow{i} + \overrightarrow{j} + 3\overrightarrow{k}$ និង $\vec{v} = 3\overrightarrow{i} + 5\overrightarrow{j} - 2\overrightarrow{k}$ ។

<u>ដំណោះស្រាយ</u>

គេមាន $\vec{u}\times\vec{v} = \begin{vmatrix} \vec{i} & \vec{j} & \vec{k} \\ 2 & 1 & 3 \\ 3 & 5 & -2 \end{vmatrix} = \begin{vmatrix} 1 & 3 \\ 5 & -2 \end{vmatrix}\vec{i} - \begin{vmatrix} 2 & 3 \\ 3 & -2 \end{vmatrix}\vec{j} + \begin{vmatrix} 1 & 2 \\ 3 & 5 \end{vmatrix}\vec{k}$

$$= (-2-15)\overrightarrow{i} - (-4-9)\overrightarrow{j} + (10-3)\overrightarrow{k} = -17\overrightarrow{i} + 13\overrightarrow{j} + 7\overrightarrow{k}$$

$$\therefore \quad |\vec{u}\times\vec{v}| = \sqrt{(-7)^2 + (13)^2 + (7)^2} = \sqrt{507}$$

២.៤. លក្ខណៈនៃផលគុណពីរវ៉ិចទ័រ

បើ $\vec{u}, \vec{v}$ និង $\vec{w}$ ជាវ៉ិចទ័រក្នុងលំហ និង c ជាចំនួនពិត គេបាន៖

១. $\vec{u}\times\vec{v} = -(\vec{v}\times\vec{u})$

២. $\vec{u}\times(\vec{u}+\vec{w}) = \vec{u}\times\vec{v} + \vec{u}\times\vec{w}$

៣. $c(\vec{u}\times\vec{v}) = (c\vec{u})\times\vec{v} = \vec{u}\times(c\vec{v})$

៤. $\vec{u}\times\vec{0} = \vec{0}\times\vec{u} = \vec{0}$

៥. $\vec{u}\times\vec{u} = \vec{0}$

៦. $\vec{u}.(\vec{v}\times\vec{w}) = (\vec{u}\times\vec{v}).\vec{w}$ ។

សម្រាយបញ្ជាក់

បើតាង $\vec{u} = (u_1, u_2, u_3), \vec{v} = (v_1, v_2, v_3)$ និង $\vec{w} = (w_1, w_2, w_3)$ និង $c \in \mathbb{R}$

១. តាមសមីការ (២.១) គេបាន $\vec{u}\times\vec{v} = (u_2v_3 - u_3v_2)\vec{i} - (u_1v_3 - u_3v_1)\vec{j} + (u_1v_2 - u_2v_1)\vec{k}$

$$= -\left[(u_3v_2 - v_2v_3)\overrightarrow{i} - (u_3v_1 - u_1v_3)\overrightarrow{j} + (u_2v_1 - u_1v_2)\overrightarrow{k}\right]$$

$$\therefore \quad \vec{u}\times\vec{v} = -\vec{v}\times\vec{u}$$

២. តាមសមីការ (២.១) គេបាន

$$\vec{u}\times(\vec{v}+\vec{w}) = [u_2(v_3+w_3)-u_3(v_2+w_2)]\,\vec{i}-[u_1(v_3+w_3)-u_3(v_1+w_1)]\,\vec{j}$$

$$+[u_1(v_2+w_2)-u_2(v_1+w_1)]\,\vec{k}$$

$$=(u_2v_3+u_2w_3-u_3v_2-u_3w_2)\,\overrightarrow{i}-(u_1v_3+u_1w_3-u_3v_1-u_3w_1)\,\overrightarrow{j}$$

$$+(u_1v_2+u_1w_2-u_2v_1-u_2w_1)\,\overrightarrow{k}$$

$$=(u_2v_3-u_3v_2)\,\overrightarrow{i}+(u_2w_3-u_3w_2)\,\overrightarrow{i}-(u_1v_3-u_3v_1)\,\overrightarrow{j}-(u_1w_3-u_3w_1)\,\overrightarrow{j}$$

$$+(u_1v_2-u_2v_1)\,\overrightarrow{k}+(u_1w_2-u_2w_1)\,\overrightarrow{k}$$

$$=\left[(u_2v_3-u_3v_2)\,\overrightarrow{i}-(u_1v_3-u_3v_1)\,\overrightarrow{j}+(u_1v_2-u_2v_1)\,\overrightarrow{k}\right]$$

$$+\left[(u_2w_3-u_3w_2)\,\overrightarrow{i}-(u_1w_3-u_3w_1)\,\overrightarrow{j}+(u_1w_2-u_2w_1)\,\overrightarrow{k}\right]$$

$$\therefore\quad \vec{u}\times(\vec{v}+\vec{w}) = \vec{u}\times\vec{v}+\vec{u}\times\vec{w}$$

៣. ចំពោះ $c\in\mathbb{R}$ គេបាន $\vec{u}\times\vec{v}=(u_2v_3-u_3v_2)\vec{i}-(u_1v_3-u_3v_1)\vec{j}+(u_1v_2-u_2v_1)\vec{k}$

នាំឲ្យ $(c\vec{u})\times\vec{v}=c\left[(u_2v_3-u_3v_2)\vec{i}-(u_1v_3-u_3v_1)\vec{j}+(u_1v_2-u_2v_1)\vec{k}\right]$

$$=(cu_2v_3-cu_3v_2)\vec{i}-(cu_1v_3-cu_3v_1)\vec{j}+(cu_1v_2-cu_2v_1)\vec{k}$$

$$=(u_2cv_3-u_3cv_2)\vec{i}-(u_1cv_3-u_3cv_1)\vec{j}+(u_1cv_2-u_2cv_1)\vec{k}$$

$$=\vec{u}\times(c\vec{v})$$

$$\therefore\quad c(\vec{u}\times\vec{v})=(c\vec{u})\times\vec{v}=\vec{u}\times(c\vec{v})$$

៤. គេបាន $\vec{u}\times\vec{0}=(u_2\times 0-u_3\times 0)\vec{i}-(u_1\times 0-u_3\times 0)\vec{j}+(u_1\times 0-u_2\times 0)\vec{k}$

$$=0\,\overrightarrow{i}+0\,\overrightarrow{j}+0\,\overrightarrow{k}$$

$$=-(0\,\overrightarrow{i}+0\,\overrightarrow{j}+0\,\overrightarrow{k})$$

$$=-\vec{0}\times\vec{u}$$

$$=\vec{0}$$

$$\therefore\quad \vec{u}\times\vec{0}=\vec{0}\times\vec{u}=\vec{0}$$

៥. គេបាន $\vec{u}\times\vec{u}=(u_2u_3-u_3u_2)\vec{i}-(u_1u_3-u_3u_1)\vec{j}+(u_1u_2-u_2u_1)\vec{k}$

$$=0\,\overrightarrow{i}+0\,\overrightarrow{j}+0\,\overrightarrow{k}$$

$$\therefore\quad \vec{u}\times\vec{u}=\vec{0}$$

៦. តាមសមីការ (២.១)

គេបាន $\vec{u}\times\vec{v}=(u_2v_3-u_3v_2)\vec{i}-(u_1v_3-u_3v_1)\vec{j}+(u_1v_2-u_2v_1)\vec{k}$

នាំឲ្យ $(\vec{u}\times\vec{v}).\vec{w}=(u_2v_3-u_3v_2)w_1-(u_1v_3-u_3v_1)w_2+(u_1v_2-u_2v_1)w_3$

$$=u_2v_3w_1-u_3v_2w_1-u_1v_3w_2+u_3v_1w_2+u_1v_2w_3-u_2v_1w_3 \qquad (I)$$

$$\vec{v}\times\vec{w}=(v_2w_3-v_3w_2)\vec{i}-(v_1w_3-v_3w_1)\vec{j}+(v_1w_2-v_2w_1)\vec{k}$$

នាំឲ្យ $\vec{u}.(\vec{v}\times\vec{w})=(v_2w_3-v_3w_2)u_1-(v_1w_3-v_3w_1)u_2+(v_1w_2-v_2w_1)u_3$

$$=u_1v_2w_3-u_1v_3w_2-u_2v_1w_3+u_2v_3w_1+u_3v_1w_2-u_3v_2w_1 \qquad (II)$$

តាម (I) និង (II) គេបាន $\vec{u}.(\vec{v}\times\vec{w})=(\vec{u}\times\vec{v}).\vec{w}$

ឧទាហរណ៍ ២.៧. គេមានវ៉ិចទ័រ $\vec{u}=\left(\frac{2}{3},\frac{1}{3},\frac{2}{3}\right)$ និង $\vec{v}=\left(-\frac{\sqrt{2}}{2},0,\frac{\sqrt{2}}{2}\right)$ ។

ក. ផ្ទៀងផ្ទាត់ថា $\vec{u},\vec{v}$ ជាវ៉ិចទ័រឯកត្តា និង អរតូកូណាល់គ្នា ។

ខ. កំណត់គ្រប់វ៉ិចទ័រ $\vec{w}$ ដែលវ៉ិចទ័រ $(\vec{u},\vec{v},\vec{w})$ ជាគោលអរតូណរម៉ាល់ ។

ដំណោះស្រាយ

ក. ផ្ទៀងផ្ទាត់ថា $\vec{u},\vec{v}$ ជាវ៉ិចទ័រឯកត្តា និង អរតូកូណាល់គ្នា ។

គេមាន $\vec{u}=\left(\frac{2}{3},\frac{1}{3},\frac{2}{3}\right)\Longrightarrow|\vec{u}|=\sqrt{\left(\frac{2}{3}\right)^2+\left(\frac{1}{3}\right)^2+\left(\frac{2}{3}\right)^2}=\sqrt{\frac{4}{9}+\frac{1}{9}+\frac{4}{9}}=1$

$$\vec{v}=\left(-\frac{\sqrt{2}}{2},0,\frac{\sqrt{2}}{2}\right)\Longrightarrow|\vec{v}|=\sqrt{\left(-\frac{\sqrt{2}}{2}\right)^2+0^2+\left(-\frac{\sqrt{2}}{2}\right)^2}=\sqrt{\frac{2}{4}+\frac{2}{4}}=1$$

គេបាន $\vec{u}.\vec{v}=\left(\frac{2}{3},\frac{1}{3},\frac{2}{3}\right)\left(-\frac{\sqrt{2}}{2},0,\frac{\sqrt{2}}{2}\right)=\left(\frac{1}{3}\right)\left(-\frac{\sqrt{2}}{2}\right)+\left(\frac{2}{3}\right)(0)+\left(\frac{2}{3}\right)\left(\frac{\sqrt{2}}{2}\right)=0$

ដោយ $|\vec{u}|=|\vec{v}|=1$ នោះគេបាន $\vec{u},\vec{v}$ ជាវ៉ិចទ័រឯកត្តា និង $\vec{u}.\vec{v}=0$ នោះគេបាន $\vec{u}$ និង $\vec{v}$ អរតូណរម៉ាល់នឹងគ្នា

ខ. កំណត់គ្រប់វ៉ិចទ័រ $\vec{w}$ ដែលវ៉ិចទ័រ $(\vec{u},\vec{v},\vec{w})$ ជាគោលអរតូណរម៉ាល់

គេបាន $\vec{w}=\vec{u}\times\vec{v}=\begin{vmatrix}\overrightarrow{i} & \overrightarrow{j} & \overrightarrow{k}\\ \frac{2}{3} & \frac{1}{3} & \frac{2}{3}\\ -\frac{\sqrt{2}}{2} & 0 & \frac{\sqrt{2}}{2}\end{vmatrix}=\begin{vmatrix}\frac{1}{3} & \frac{2}{3}\\ 0 & \frac{\sqrt{2}}{2}\end{vmatrix}\overrightarrow{i}-\begin{vmatrix}\frac{2}{3} & \frac{2}{3}\\ -\frac{\sqrt{2}}{2} & \frac{\sqrt{2}}{2}\end{vmatrix}\overrightarrow{j}+\begin{vmatrix}\frac{2}{3} & \frac{1}{3}\\ -\frac{\sqrt{2}}{2} & 0\end{vmatrix}\overrightarrow{k}$

$$=\left(\frac{1}{3}\times\frac{\sqrt{2}}{2}-0\times\frac{2}{3}\right)\overrightarrow{i}-\left(\frac{2}{3}\times\frac{\sqrt{2}}{2}+\frac{\sqrt{2}}{2}\times\frac{2}{3}\right)\overrightarrow{j}+\left(\frac{2}{3}\times0+\frac{\sqrt{2}}{2}\times\frac{1}{3}\right)\overrightarrow{k}$$

$$=\frac{\sqrt{2}}{6}\overrightarrow{i}-\frac{2\sqrt{2}}{3}\overrightarrow{j}+\frac{\sqrt{2}}{6}\overrightarrow{k}$$

២.៥. ផលគុណចម្រុះនៃបីវ៉ិចទ័រក្នុងលំហ

និយមន័យ ២.១. គេមានវ៉ិចទ័រ $\vec{u},\vec{v}$ និង $\vec{w}$ នៅក្នុងលំហ ។ ផលគុណចម្រុះនៃ $\vec{u},\vec{v}$ និង $\vec{w}$ តាមលំដាប់គឺជាចំនួនពិតកំណត់ដោយ $\vec{u}.(\vec{v}\times\vec{w})$ ។

ទ្រឹស្តីបទ ២.៣. បើគេមានវ៉ិចទ័រ $\vec{u}=u_1\vec{i}+u_2\vec{j}+u_3\vec{k}, \vec{v}=v_1\vec{i}+v_2\vec{j}+v_3\vec{k}$ និង $\vec{w}=w_1\vec{i}+w_2\vec{j}+w_3\vec{k}$ នោះផលគុណចម្រុះនៃបីវ៉ិចទ័រ $\vec{u},\vec{v}$ និង $\vec{w}$ តាមលំដាប់នៅក្នុងលំហកំណត់ដោយ ៖

$$\vec{u}.(\vec{v}\times\vec{w})=\begin{vmatrix}u_1 & u_2 & u_3\\ v_1 & v_2 & v_3\\ w_1 & w_2 & w_3\end{vmatrix}$$



១. មាឌរបស់ប្រលេពីប៉ែតដែលសង់លើវ៉ិចទ័រ $\vec{u},\vec{v}$ សង់លើវ៉ិចទ័រ $\vec{u},\vec{v}$ និង $\vec{w}$ គឺ $V=|\vec{u}.(\vec{v}\times\vec{w})|$ ។

២. មាឌតេត្រាអ៊ែត $ABCD$ គឺ $W=\dfrac{1}{6}|\vec{u}.(\vec{v}\times\vec{w})|$ ឬ $W=\dfrac{1}{6}|\vec{AD}.(\overrightarrow{AB}\times\overrightarrow{AC})|$ បានន័យថាយកមាឌប្រលេពីប៉ែតចែកនឹង 6 ។

១. តាង θ ជាមុំផ្គុំរវាង $\vec{v}$ និង h ដែល h ជាកម្ពស់ប្រលេពីប៉ែត

ដោយមាឌប្រលេពីប៉ែត = ក្រឡាផ្ទៃបាត $\times$ កម្ពស់

$V = |\vec{u}\times\vec{v}|.h$, $h = |\vec{w}|.\cos\theta$, $0^\circ < \theta < \dfrac{\pi}{2}$

គេបាន

$$V = |\vec{u}\times\vec{v}||\vec{w}|\cos\theta \qquad (២.២)$$

ម្យ៉ាងទៀត

$$(\vec{u}\times\vec{v}).\vec{w} = |\vec{u}\times\vec{w}|.|\vec{w}|\cos\theta \qquad (២.៣)$$



តាម (២.២) និង (២.៣) គេបាន $V = (\vec{u}\times\vec{v}).\vec{w}$

ករណី $\dfrac{\pi}{2} < \theta < \pi \Rightarrow \cos\theta < 0$

គេបាន $V = -(\vec{u}\times\vec{v}).\vec{w} \Rightarrow V = |(\vec{u}\times\vec{v}).\vec{w}|$

ដូចនេះ មាឌប្រលេពីប៉ែត $V = |\vec{v}.(\vec{u}\times\vec{w})|$

២. តាមរូបមន្ត

មាឌតេត្រាអ៊ែត $= \dfrac{1}{3}$ ក្រលាផ្ទៃបាទ $\times$ កម្ពស់

ដោយផ្ទៃបាតជាត្រីកោណ $\dfrac{1}{2}|\vec{u}\times\vec{v}|$ និង

កម្ពស់ $h = |\vec{v}|.\cos\theta$, $0^\circ < \theta < \dfrac{\pi}{2}$

គេបាន $W = \dfrac{1}{3}\times\dfrac{1}{2}|\vec{u}\times\vec{v}|.|\vec{w}|\cos\theta$

$= \dfrac{1}{6}(\vec{u}\times\vec{v}).\vec{w}$ (តាមនិយន័យ)

ករណី $\dfrac{\pi}{2} < \theta < \pi \Rightarrow \cos\theta < 0$

គេបាន $W = -\dfrac{1}{6}(\vec{u}\times\vec{v}).\vec{w}$

$\Rightarrow W = \dfrac{1}{6}|(\vec{u}\times\vec{v}).\vec{w}|$

ដូចនេះ មាឌប្រលេពីប៉ែត $W = \dfrac{1}{6}|(\vec{u}\times\vec{v}).\vec{w}|$



ឧទាហរណ៍ ២.៨. ក្នុងតម្រុយ $(o, \vec{i}, \vec{j}, \vec{k})$ មានទិសដៅវិជ្ជមាន គេឲ្យចំណុច $A(1,0,2)$, $B(1,1,3)$ និង $C(2,1,2)$ ។

១. គណនា $\overrightarrow{AB}\times\overrightarrow{AC}$ រួចទាញរកផ្ទៃក្រឡានៃត្រីកោណ ABC ។

២. គណនា $\overrightarrow{AO}\cdot(\overrightarrow{AB}\times\overrightarrow{AC})$ រួចទាញរកមាឌនៃប្រលេពីប៉ែតដែលមានវិចទ័រ $\overrightarrow{AB}, \overrightarrow{AC}$ និងមាឌនៃចតុមុខ $OABC$ ។

ដំណោះស្រាយ

១. គណនា $\overrightarrow{AB}\times\overrightarrow{AC}$

ដោយ $\overrightarrow{AB}=(1-1,1-0,3-2)=(0,1,1)$

$\overrightarrow{AC}=(2-1,1-0,2-2)=(1,1,0)$

គេបាន $\overrightarrow{AB}\times\overrightarrow{AC}=\begin{vmatrix}\overrightarrow{i} & \overrightarrow{j} & \overrightarrow{k}\\ 0 & 1 & 1\\ 1 & 1 & 0\end{vmatrix}=\overrightarrow{i}\begin{vmatrix}1 & 1\\ 1 & 0\end{vmatrix}-\overrightarrow{j}\begin{vmatrix}0 & 1\\ 1 & 0\end{vmatrix}+\overrightarrow{k}\begin{vmatrix}0 & 1\\ 1 & 1\end{vmatrix}$

$=-\overrightarrow{i}+\overrightarrow{j}-\overrightarrow{k}$

ផ្ទៃក្រឡានៃត្រីកោណ ABC

គេបាន $S_{\triangle ABC}=\frac{1}{2}|\overrightarrow{AB}\times\overrightarrow{AC}|=\sqrt{1^2+1^2+1^2}=\sqrt{3}$ ឯកតាក្រឡាផ្ទៃ

២. គណនា $\overrightarrow{AO}\cdot(\overrightarrow{AB}\times\overrightarrow{AC})$

ដោយ $\overrightarrow{AO}=(0-1,0-0,0-2)=(-1,0,-2)$

គេបាន $\overrightarrow{AO}.(\overrightarrow{AB}\times\overrightarrow{AC})=(-1)(-1)+(0)(1)+(-2)(-1)$

$=1+0+2=3$

មាឌនៃប្រលេពីប៉ែតដែលមានវ៉ិចទ័រ $\overrightarrow{AB},\overrightarrow{AC}$

គេបាន $V_{OABC}=|\overrightarrow{AO}.(\overrightarrow{AB}\times\overrightarrow{AC})=|3|=3$ ឯកតាមាឌ

មាឌនៃចតុមុខ $OABC$

គេបាន $W_{OABC}=\frac{1}{6}\left|\overrightarrow{AO}.(\overrightarrow{AB}\times\overrightarrow{AC})\right|=\frac{1}{6}\times 3=\frac{1}{2}$ ឯកតាមាឌ

ផ្នែកទី ១

លំហាត់ និងដំណោះស្រាយ

លំហាត់ ១. គេឲ្យម៉ាទ្រីស A, B និង C កំណត់ដោយ $A = \begin{pmatrix} 2 & -1 \\ 3 & 1 \end{pmatrix}, B = \begin{pmatrix} 1 & 0 \\ 0 & -2 \end{pmatrix}$ និង $C = \begin{pmatrix} -2 & 1 \\ -1 & 1 \end{pmatrix}$ ។ គណនាម៉ាទ្រីស $D = a + 2B - C$ ។

ដំណោះស្រាយ

គេបាន $D = \begin{pmatrix} 2 & -1 \\ 3 & 1 \end{pmatrix} + 2\begin{pmatrix} 1 & 0 \\ 0 & -2 \end{pmatrix} - \begin{pmatrix} -2 & 1 \\ -1 & 1 \end{pmatrix}$

$$= \begin{pmatrix} 2+2\times 1-(-2) & -1+2\times 0-1 \\ 3+2\times 0-(-1) & 1+2\times(-2)-1 \end{pmatrix}$$

ដូចនេះ $\boxed{D = \begin{pmatrix} 6 & -2 \\ 4 & -4 \end{pmatrix}}$

លំហាត់ ២. គេឲ្យម៉ាទ្រីស $A = \begin{bmatrix} 4 & -3 \\ 0 & 1 \end{bmatrix} \quad B = \begin{bmatrix} 1 & 2 \\ 0 & -3 \end{bmatrix} \quad C = \begin{bmatrix} 4 & 3 & 2 & 0 \\ 0 & 4 & 3 & 4 \\ 3 & 6 & 1 & -7 \\ 4 & 6 & 2 & -3 \end{bmatrix}$

និង $D = \begin{bmatrix} 5 & 3 \\ 2 & 1 \end{bmatrix}$ ។ គណនា $A+B, A+C, A+B+D$ ។

ដំណោះស្រាយ

- $A + B = \begin{bmatrix} 4 & -3 \\ 0 & 1 \end{bmatrix} + \begin{bmatrix} 1 & 2 \\ 0 & -3 \end{bmatrix} = \begin{bmatrix} 4+1 & -3+2 \\ 0+0 & 1-3 \end{bmatrix} = \begin{bmatrix} 5 & -1 \\ 0 & -2 \end{bmatrix}$

  ដូចនេះ $\boxed{A + B == \begin{bmatrix} 5 & -1 \\ 0 & -2 \end{bmatrix}}$

- $A + C$ មិនអាចធ្វើការបូកបានទេ ព្រោះវាមានលំដាប់ខុសគ្នា

- $A + B + D = \begin{bmatrix} 4 & -3 \\ 0 & 1 \end{bmatrix} + \begin{bmatrix} 1 & 2 \\ 0 & -3 \end{bmatrix} + \begin{bmatrix} 5 & 3 \\ 2 & 1 \end{bmatrix} = \begin{bmatrix} 4+1+5 & -3+2+3 \\ 0+0+2 & 1-3+1 \end{bmatrix} = \begin{bmatrix} 10 & 2 \\ 2 & -1 \end{bmatrix}$

ដូចនេះ $\boxed{A+B=\begin{bmatrix}5 & -1\\ 0 & -2\end{bmatrix};\quad A+B+D=\begin{bmatrix}10 & 2\\ 2 & -1\end{bmatrix}}$

លំហាត់ ៣. គណនា $A+B, A-B$ ដែល $A=\begin{bmatrix}4 & 1 & 3\\ 3 & 0 & 2\\ 4 & -3 & 5\end{bmatrix}$ និង $B=\begin{bmatrix}2 & 1 & 3\\ 5 & 0 & -2\\ 6 & 3 & 0\end{bmatrix}$

ដំណោះស្រាយ

- $A+B=\begin{bmatrix}4 & 1 & 3\\ 3 & 0 & 2\\ 4 & -3 & 5\end{bmatrix}+\begin{bmatrix}2 & 1 & 3\\ 5 & 0 & -2\\ 6 & 3 & 0\end{bmatrix}=\begin{bmatrix}4+2 & 1+1 & 3+3\\ 3+5 & 0+0 & 2-2\\ 4+6 & -3+3 & 5+0\end{bmatrix}=\begin{bmatrix}6 & 2 & 6\\ 8 & 0 & 0\\ 10 & 0 & 5\end{bmatrix}$
- $A-B=\begin{bmatrix}4 & 1 & 3\\ 3 & 0 & 2\\ 4 & -3 & 5\end{bmatrix}-\begin{bmatrix}2 & 1 & 3\\ 5 & 0 & -2\\ 6 & 3 & 0\end{bmatrix}=\begin{bmatrix}4-2 & 1-1 & 3-3\\ 3-5 & 0-0 & 2+2\\ 4-6 & -3-3 & 5-0\end{bmatrix}=\begin{bmatrix}2 & 0 & 0\\ -2 & 0 & 4\\ -2 & -6 & 5\end{bmatrix}$

ដូចនេះ $\boxed{A+B=\begin{bmatrix}6 & 2 & 6\\ 8 & 0 & 0\\ 10 & 0 & 5\end{bmatrix};\quad A-B=\begin{bmatrix}2 & 0 & 0\\ -2 & 0 & 4\\ -2 & -6 & 5\end{bmatrix}}$

លំហាត់ ៤. គណនា $4A, -2B$ និង $4A-2B$

គេឲ្យ $A=\begin{bmatrix}3 & 2 & 0\\ -1 & 4 & 5\\ 0 & 3 & 4\end{bmatrix}$ និង $B=\begin{bmatrix}2 & 5 & 6\\ 0 & -1 & -1\\ 2 & 3 & 4\end{bmatrix}$

ដំណោះស្រាយ

- $4A=4\begin{bmatrix}3 & 2 & 0\\ -1 & 4 & 5\\ 0 & 3 & 4\end{bmatrix}=\begin{bmatrix}12 & 8 & 0\\ -4 & 16 & 20\\ 0 & 12 & 16\end{bmatrix}$

$-2B=2\begin{bmatrix}2 & 5 & 6\\ 0 & -1 & -1\\ 2 & 3 & 4\end{bmatrix}=\begin{bmatrix}-4 & -10 & -12\\ 0 & 2 & 2\\ -4 & -6 & -8\end{bmatrix}$

- $4A-2B=\begin{bmatrix}12 & 8 & 0\\ -4 & 16 & 20\\ 0 & 12 & 16\end{bmatrix}+\begin{bmatrix}-4 & -10 & -12\\ 0 & 2 & 2\\ -4 & -6 & -8\end{bmatrix}=\begin{bmatrix}8 & -2 & -12\\ -4 & 18 & 22\\ -4 & 6 & 8\end{bmatrix}$

ដូចនេះ $\boxed{4A=\begin{bmatrix}12 & 8 & 0\\ -4 & 16 & 20\\ 0 & 12 & 16\end{bmatrix}\ ;\quad -2B=\begin{bmatrix}-4 & -10 & -12\\ 0 & 2 & 2\\ -4 & -6 & -8\end{bmatrix}\quad 4A-2B=\begin{bmatrix}8 & -2 & -12\\ -4 & 18 & 22\\ -4 & 6 & 8\end{bmatrix}}$

លំហាត់ ៥. គេឲ្យ $A=\begin{pmatrix}2 & 1\\ -1 & 0\\ 3 & 1\end{pmatrix}$ និង $B=\begin{pmatrix}3 & 1 & -1 & \\ 4 & -2 & 1 & 0\end{pmatrix}$ ។ គណនា AB និង BA ។

ដំណោះស្រាយ

គេបាន $AB=\begin{pmatrix}2 & 1\\ -1 & 0\\ 3 & 1\end{pmatrix}\begin{pmatrix}3 & 1 & 5 & -1\\ 4 & -2 & 1 & 0\end{pmatrix}$

$$=\begin{pmatrix}2(3)+1(4) & 2(1)+1(-2) & 2(5)+1(1) & 2(-1)+1(0)\\ -1(3)+0(4) & -1(1)+0(-2) & -1(5)+0(1) & -1(-1)+0(0)\\ 3(3)+1(4) & 3(1)+1(2) & 3(5)+1(1) & 3(-1)+1(0)\end{pmatrix}$$

$$=\begin{pmatrix}10 & 0 & 11 & -2\\ -3 & -1 & -5 & 1\\ 13 & 1 & 16 & -3\end{pmatrix}$$

ចំពោះ BA មិនអាចធ្វើប្រមាណវិធីបានទេ ។

លំហាត់ ៦. គណនាម៉ាទ្រីស $A\times B$ និង $C\times D$ ដែល $A=\begin{bmatrix}-2 & 0 & 1\\ 3 & 4 & 2\end{bmatrix}$, $B=\begin{bmatrix}6 & 0\\ 1 & -2\\ 3 & 5\end{bmatrix}$

, $C=\begin{bmatrix}3 & -2 & 0\\ 1 & 5 & 4\\ 3 & 0 & 3\end{bmatrix}$ និង $D=\begin{bmatrix}4 & -1 & 2\end{bmatrix}$

ដំណោះស្រាយ

គេបាន$A \times B = \begin{bmatrix} -2 & 0 & 1 \\ 3 & 4 & 2 \end{bmatrix} \begin{bmatrix} 6 & 0 \\ 1 & -2 \\ 3 & 5 \end{bmatrix}$

$$= \begin{bmatrix} (-2)(6) + (0)(1) + (1)(3) & (-2)(0) + (0)(-2) + (1)(5) \\ (3)(6) + (4)(1) + (2)(3) & (3)(0) + (4)(-2) + (2)(5) \end{bmatrix}$$

$$= \begin{bmatrix} -12 + 0 + 3 & 0 + 0 + 5 \\ 18 + 4 + 6 & 0 + (-8) + 10 \end{bmatrix} = \begin{bmatrix} -9 & 5 \\ 28 & 2 \end{bmatrix}$$

ហើយ $C \times D = \begin{bmatrix} 3 & -2 & 0 \\ 1 & 5 & 4 \\ 3 & 0 & 3 \end{bmatrix} \begin{bmatrix} 4 \\ -1 \\ 2 \end{bmatrix} = \begin{bmatrix} (3)(4) + (-2)(-1) + (0)(2) \\ (1)(4) + (5)(-1) + (4)(-1) \\ (3)(4) + (0)(-1) + (3)(2) \end{bmatrix}$

$$= \begin{bmatrix} 12 + 2 + 0 \\ 4 + (-5) + (-4) \\ 12 + (-1) + 6 \end{bmatrix} = \begin{bmatrix} 14 \\ -5 \\ 17 \end{bmatrix}$$

